**អង្គការសហប្រជាជាតិ** **A**/57/769

**មហាសន្និបាត**

ការចែកចាយទូទៅ
ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣
អត្ថបទដើម: អង់គ្លេស

សម័យប្រជុំលើកទី ៥៧
ចំណុចនៃរបៀបវារៈលេខ ១០៩ (ខ)
**បញ្ហាសិទ្ធិមនុស្ស: បញ្ហាសិទ្ធិមនុស្សរួមទាំងមធ្យោបាយជាជំនួសសំរាប់**
**ដោះស្រាយ ដើម្បីធ្វើឱ្យប្រសើរឡើងដល់ការប្រើប្រាស់សិទ្ធិមនុស្ស**
**និងសេរីភាពជាមូលដ្ឋានឱ្យបានប្រកបដោយប្រសិទ្ធិភាព**

# របាយការណ៍របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិស្តីការជំនុំជំរះមេដឹកនាំខ្មែរក្រហម

*សេចក្តីសង្ខេប:*

តំណាងរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ និងតំណាងរបស់កម្ពុជាបានធ្វើការចរចាគ្នា និងបានរៀបចំចងក្រងអត្ថបទសេចក្តីព្រាងនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាស្តីពីការកាត់សេចក្តីក្រោមច្បាប់កម្ពុជាចំពោះបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិប-តេយ្យ។ សេចក្តីព្រាង នៃកិច្ចព្រមព្រៀងចែងពីការបង្កើតឱ្យមានអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការជាតិនៃកម្ពុជា ដែលនឹងត្រូវបានបង្កើតឡើង និងដំណើរការការងារដោយជំនួយឧបត្ថម្ភពីអន្តរជាតិ។ អង្គជំនុំជំរះវិសាមញ្ញមានសមត្ថកិច្ចសំរាប់ជំនុំជំរះមេដឹកជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋ-កម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី ១៧ មេសា ១៩៧៥ ដល់ថ្ងៃទី ៦ មករា ១៩៧៩។

លោកអគ្គលេខាធិការអង្គការសហប្រជាជាតិចាត់ទុកថាសេចក្តីព្រាងនៃកិច្ចព្រមព្រៀងនេះ ត្រូវបានធ្វើការកែលំអយ៉ាងច្រើនលើសេចក្តីព្រាងដែលបានពិភាក្សា នៅក្នុងអំឡុងពេលនៃការចរចាកន្លងមក របស់លោកជាមួយរដ្ឋាភិ-បាលកម្ពុជា ជាពិសេសលើបទប្បញ្ញត្តិស្តីពីលក្ខន្តិកៈនៃកិច្ចព្រមព្រៀង និងបទប្បញ្ញតិនៃកិច្ចព្រមព្រៀងនេះ ស្តីពីនីតិវិធីដែលត្រូវអនុវត្តតាមក្នុងការចោទប្រកាន់ និងជំនុំជំរះ។ ការចរចាគ្នាដែលនាំឱ្យមានការរៀបចំតាក់តែងជាអត្ថបទសេចក្តី

ព្រាងនៃកិច្ចព្រមព្រៀងនេះត្រូវបានអូសបន្លាយពេលវេលា ហើយពេលខ្លះមានការលំបាក។ មជ្ឈដ្ឋានខ្លះនៅមានការស្រពិចស្រពិលនៅឡើយ ស្តីពីជំនឿទុកចិត្តចំពោះអង្គជំនុំជំរះវិសាមញ្ញ ដោយឯករាជ្យភាពនៃតុលាការកម្ពុជាមានលក្ខណៈមិនពិតប្រាកដ។ ទោះជាយ៉ាងណាក្តី លោកអគ្គលេខាធិការអង្គការសហប្រជាជាតិសង្ឃឹមថា នៅក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ រដ្ឋាភិបាលមុខជានឹងអនុវត្តឱ្យបានពេញលេញនូវកាតព្វកិច្ចដែលខ្លួនត្រូវទទួលខុសត្រូវ។ សំខាន់បំផុតគឺត្រូវកត់សំគាល់ឱ្យបានច្បាស់ថា ផ្អែកតាមលក្ខខណ្ឌនៃសេចក្តីព្រាងកិច្ចព្រមព្រៀងនេះ គឺបើភាគីរដ្ឋាភិបាលមានការគេចកែមិនអនុវត្តតាមកាតព្វកិច្ចដែលខ្លួនត្រូវទទួលខុសត្រូវនោះ អាចនឹងនាំឱ្យអង្គការសហប្រជាជាតិដកកិច្ចសហប្រតិបត្តិការ និងជំនួយរបស់ខ្លួនចេញពីកិច្ចដំណើរការនេះ។

សេចក្តីព្រាងនៃកិច្ចព្រមព្រៀងត្រូវបានចុះហត្ថលេខាសង្ខេប ដើម្បីបញ្ជាក់ថាជាអត្ថបទដែលគណៈប្រតិភូទាំងពីរបានរៀបចំតាក់តែងឡើង។ ឥឡូវនេះគឺជាពេលដែលមហាសន្និបាតជាអ្នកត្រូវសំរេចថាតើអង្គការសហប្រជាជាតិគួរត្រូវបន្ត ឬមិនបន្តការពិភាក្សាដើម្បីសំរេចចុះហត្ថលេខា លើកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលកម្ពុជា ដោយផ្អែកលើសេចក្តីព្រាងនោះ។

របាយការណ៍ក៏បានរៀបរាប់ផងដែរ អំពីសេចក្តីត្រូវការនៃអង្គជំនុំជំរះវិសាមញ្ញ និងស្ថាប័នពាក់ព័ន្ធទាក់ទងនឹងបញ្ហាថវិកា គ្រឿងបរិក្ខារ សេវា និងបុគ្គលិក។ របាយការណ៍ក៏បានបង្ហាញផងដែរអំពីជំរើសផ្សេងៗ ក្នុងការផ្តល់ជំនួយឧបត្ថម្ភដែលអង្គការសហប្រជាជាតិត្រូវផ្តល់តាមលក្ខខណ្ឌនៃសេចក្តីព្រាងនៃកិច្ចព្រមព្រៀងនេះ ហើយសំរេចថា វិភាគទានដែលបានសំរេចកំណត់រួចហើយ គឺជាយន្តការតែមួយគត់ដែលអាចឱ្យការងារដំណើរការបានប្រកបដោយនិរន្តរភាព ហើយដែលធានាឱ្យការបង្កើតអង្គជំនុំជំរះវិសាមញ្ញបានឆាប់ទាន់ពេលវេលា និងចាប់ផ្តើមដំណើរការការងាររបស់ខ្លួនបានយ៉ាងឆាប់រហ័សបំផុត។

## I- សេចក្តីផ្តើម

១- នៅក្នុងសេចក្តីសំរេចចិត្តរបស់ខ្លួនលេខ 57/228 ចុះថ្ងៃទី ១៨ ធ្នូ ២០០២ មហាសន្និបាតអង្គការសហប្រជាជាតិបានស្នើឱ្យខ្ញុំចាប់ផ្តើមបន្តការចរចាដោយគ្មានការពន្យាពេល ដើម្បីសំរេចយោបល់រួមលើកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតអង្គជំនុំជំរះវិសាមញ្ញនៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ (ដែលនៅក្នុងនោះហៅថា "អង្គជំនុំជំរះវិសាមញ្ញ") ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

២- មហាសន្និបាតអង្គការសហប្រជាជាតិក៏បានស្នើឱ្យខ្ញុំដាក់ជូនមហាសន្និបាត ក្នុងរយៈពេល ៩០ ថ្ងៃ យ៉ាងយូរចាប់គិតពីថ្ងៃអនុម័តសេចក្តីសំរេចចិត្តនូវរបាយការណ៍ស្តីពីការអនុវត្តសេចក្តីសំរេចចិត្ត ជាពិសេសរបាយការណ៍ស្តីពីការពិគ្រោះយោបល់ និងការចរចាដែលបានធ្វើឡើងរវាងខ្ញុំនិងរដ្ឋាភិបាលកម្ពុជាស្តីពីការបង្កើតអង្គជំនុំជំរះវិសាមញ្ញ។

៣- ជាងនេះទៅទៀត មហាសន្និបាតអង្គការសហប្រជាជាតិ បានស្នើឱ្យខ្ញុំដាក់បញ្ចូលអនុសាសន៍ក្នុងរបាយការណ៍របស់ខ្ញុំស្តីពីកិច្ចដំណើរការ និងការចំណាយលើការងារនៃអង្គជំនុំជំរះវិសាមញ្ញប្រកបដោយប្រសិទ្ធិភាព ដោយរួមទាំងចំនួនទឹកប្រាក់ថវិកា នៃវិភាគទានស្ម័គ្រចិត្ត គ្រឿងបរិក្ខារ និងសេវា ក្នុងចំណោមសេចក្តីត្រូវការដទៃទៀត តាមរយៈការផ្តល់បុគ្គលិកជំនាញដែលអាចត្រូវការពីរដ្ឋជាសមាជិក អង្គការអន្តររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ។

៤- នៅថ្ងៃទី ១៧ មីនា ២00៣ ខ្ញុំបានសរសេរលិខិតមួយច្បាប់ទៅប្រធានមហាសន្និបាតអង្គការសហប្រជាជាតិ ដោយផ្តល់ជូនលោក និងតាមរយៈលោក សមាជិកមហាសន្និបាតនូវរបាយការណ៍បឋមសង្ខេបស្តីពីការចរចារបស់ខ្ញុំជាមួយរដ្ឋាភិបាលកម្ពុជា (A/57/758) ។ ក្នុងលិខិតនោះ ខ្ញុំបានបញ្ជាក់ថា នៅពេលដ៏ខ្លីខាងមុខនេះ ខ្ញុំនឹងដាក់របាយការណ៍ពេញលេញមួយជូនមហាសន្និបាតអង្គការសហប្រជាជាតិ ឆ្លើយតបទៅនឹងសំណើដែលមានចែងនៅក្នុងសេចក្តីសំរេចចិត្តលេខ 57/228 ។ របាយការណ៍នេះ ត្រូវបានដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិសំរាប់គោលបំណងនោះ ។

៥- របាយការណ៍នេះមានប្រាំភាគ ។ ផ្នែកទី II រៀបរាប់ត្រួសៗ អំពីប្រវត្តិសវតាដើម ។ ផ្នែកទី III បរិយាយអំពីការបន្តចរចាឡើងវិញ រវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាដែលបានធ្វើឡើងបន្ទាប់ពីការអនុម័តលើសេចក្តីសំរេចចិត្តលេខ 57/228 ។ ផ្នែកទី IV ស្រាយបំភ្លឺពីបទប្បញ្ញត្តិនៃសេចក្តីព្រាងកិច្ចព្រមព្រៀងដែលបានរៀបចំតាក់តែងឡើងបន្ទាប់ពីមានការចរចាទាំងនេះ ។ ផ្នែកទី V រៀបរាប់ពីវិធានការទាំងឡាយដែលនឹងត្រូវចាត់ ដើម្បីសំរេចលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាដោយយកសេចក្តីព្រាងនោះធ្វើជាមូលដ្ឋាន និងដើម្បីឱ្យកិច្ចព្រមព្រៀងនោះចូលជាធរមាន ។ ផ្នែកទី VI លើកឡើងពីវិធានការជាក់ស្តែងមួយចំនួនដែលត្រូវចាត់ ដើម្បីអនុវត្តសេចក្តីព្រាងនៃកិច្ចព្រមព្រៀងនេះ ។ ជាពិសេស របាយការណ៍បាននិយាយពីជំនួយអន្តរជាតិដែលនឹងត្រូវការចាំបាច់ទាក់ទងនឹងបុគ្គលិក គ្រឿងបរិក្ខារ សេវា និងថវិកា ដើម្បីអាចបង្កើតអង្គជំនុំជំរះវិសាមញ្ញបានឆាប់រហ័ស និងធានានិរន្តរភាពនៃកិច្ចដំណើរការ និងការចំណាយប្រកបដោយប្រសិទ្ធិភាព ។ នៅក្នុងផ្នែកនេះ មានរៀបរាប់ផងដែរអំពីការប៉ាន់ប្រមាណពីលទ្ធភាពដែលមាន និងអំពីនិរន្តរភាពនៃយន្តការថវិកាដែលមហាសន្និបាតបានលើកឡើងនៅក្នុងសេចក្តីសំរេចចិត្តព្រមជាមួយនឹងដំណោះស្រាយមួយសំរាប់ជាជំរើសជូនមហាសន្និបាតធ្វើការពិចារណា ។

**II. ប្រវត្តិសវតាដើម**

៦- នៅថ្ងៃទី ២១ មិថុនា ១៩៩៧ នាយរដ្ឋមន្ត្រីទាំងពីរនៃកម្ពុជាបានផ្ញើលិខិតមួយច្បាប់មកខ្ញុំ ស្នើសុំជំនួយពីអង្គការសហប្រជាជាតិ ដើម្បីបញ្ជូនទៅកាត់ទោសនូវជនទាំងឡាយដែលទទួលខុសត្រូវចំពោះបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំបានបញ្ជូនលិខិតនោះទៅប្រធានមហាសន្និបាត និងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ នៅថ្ងៃទី ២៣ មិថុនា ១៩៩៧ (A/51/930-S/1997/488) ។ មហាសន្និបាតអង្គការសហប្រជាជាតិ នៅក្នុងសេចក្តីសំរេចចិត្តរបស់ខ្លួនលេខ 52/135 ចុះថ្ងៃទី ១២ ធ្នូ ១៩៩៧ បានស្នើសុំឱ្យខ្ញុំពិនិត្យលើសំណើនោះ ដោយរួមទាំងលទ្ធភាពក្នុងជ្រើសតាំងអ្នកជំនាញការមួយ

ក្រុមដើម្បីធ្វើការវាយតំលៃភស្តុតាងដែលមានស្រាប់ និងដើម្បីលើកសំណើរជាវិធានការបន្តទៀត។ កាលពីថ្ងៃទី ១៣ កក្កដា ១៩៩៨ ខ្ញុំបានចាត់តាំងបង្កើតជាក្រុមអ្នកជំនាញការមួយក្រុម ដើម្បីធ្វើការវាយតំលៃលើភស្តុតាងដែលមានស្រាប់ប៉ាន់ប្រមាណពីលទ្ធភាពដែលអាចធ្វើបានក្នុងការនាំខ្លួនមេដឹកនាំខ្មែរក្រហមទៅកាត់ទោស និងស្វែងរកជំរើសផ្សេងៗដើម្បីធ្វើការងារនោះ នៅចំពោះមុខយុត្តាធិការជាតិ ឬអន្តរជាតិ។ កាលពីថ្ងៃទី ១៥ មីនា ១៩៩៩ ខ្ញុំបានដាក់របាយ-ការណ៍របស់ក្រុមអ្នកជំនាញការជូនមហាសន្និបាត និងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (A/53/850-S/1999/231)។ ក្នុងរបាយការណ៍របស់ខ្លួន ក្រុមអ្នកជំនាញការបានផ្តល់ជាអនុសាសន៍ ស្តីពីការបង្កើតតុលាការអន្តរជាតិ ដើម្បីកាត់សេចក្តីមេដឹកនាំខ្មែរក្រហមដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹង មនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជ-សាសន៍ដែលបានប្រព្រឹត្តក្នុងអំឡុងពេលពីថ្ងៃទី ១៧ មេសា ១៩៧៥ ដល់ថ្ងៃទី ៧ មករា ១៩៧៩។ ប៉ុន្តែជំរើសនេះ រដ្ឋាភិបាលកម្ពុជាមិនអាចទទួលយកបានទេ។

៧- កាលពីថ្ងៃទី ១៧ មិថុនា ១៩៩៩ លោកនាយរដ្ឋមន្ត្រី ហ៊ុន សែន បានសរសេរលិខិតមកខ្ញុំម្តងទៀត ស្នើសុំឱ្យអង្គការសហប្រជាជាតិផ្តល់អ្នកជំនាញការ ដើម្បីជួយកម្ពុជាក្នុងការព្រាងច្បាប់មួយដែលនឹងចែងពីការបង្កើតតុលាការជាតិកម្ពុជាពិសេសមួយ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយដែលនឹងចែងពីចៅក្រម និងព្រះរាជអាជ្ញាបរទេសដែលត្រូវចូលរួមក្នុងកិច្ចដំណើរការរបស់តុលាការនេះ។ ឆ្លើយតបទៅនឹងសំណើនេះ ខ្ញុំបានធ្វើការចរចាជាមួយរដ្ឋាភិបាលកម្ពុជាក្នុងគោលបំណងដើម្បីឈានទៅដល់ការព្រមព្រៀងគ្នា អំពីថាតើត្រូវរៀបចំបង្កើតតុលាការមួយតាមវិធីណា ហើយតុលាការនោះត្រូវដំណើរការការងាររបស់ខ្លួនយ៉ាងដូចម្តេច? បើសិនជាអង្គការសហប្រជាជាតិត្រូវផ្តល់ ឬចាត់ចែងជំនួយដើម្បីជួយដល់ការបង្កើត និងជួយឱ្យតុលាការនេះដំណើរការ។ ការចរចាទាំងនេះ បានប្រព្រឹត្តទៅអស់រយៈពេលពីរឆ្នាំកន្លះ។ នៅខែ កម្ភៈ ២០០២ ខ្ញុំបានសំរេចថា ខ្ញុំឈប់លែងបន្តការចរចានេះតទៅទៀតហើយ។

## III. ការចរចាត្រូវបានធ្វើជាបន្ត

៨- ការបន្តចរចាឡើងវិញរួម រវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា ស្របតាមសេចក្តីសំរេចចិត្តលេខ 57/228 របស់មហាសន្និបាតអង្គការសហប្រជាជាតិ ត្រូវបានធ្វើឡើងជាពីរដំណាក់កាល។

## ក- ការចរចានៅទីក្រុងញូវយ៉ក : ខែ មករា ២០០៣

៩- ដំណាក់កាលទីមួយរួម មានការប្រជុំដើម្បីស្រាវជ្រាវជាបន្តៗគ្នាចំនួនប្រាំមួយលើក ដែលប្រារព្ធធ្វើឡើងនៅទីបញ្ជាការអង្គការសហប្រជាជាតិក្នុងចន្លោះពីថ្ងៃទី ៦ និងថ្ងៃទី ១៣ មករា ២០០៣។ រដ្ឋាភិបាលកម្ពុជាតំណាងនៅក្នុងសម័យប្រជុំទាំងនោះដោយគណៈប្រតិភូមួយក្រុមដែលដឹកនាំដោយលោក សុខ អាន ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ ប្រតិភូអង្គការសហប្រជាជាតិដឹកនាំដោយលោក ហាន់ កូរ៉ែល អគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់ និងជាទីប្រឹក្សាច្បាប់។ ការប្រជុំដើម្បីស្រាវជ្រាវទាំងនេះ មានគោលបំណងធ្វើឱ្យភាគីទាំងពីរគឺ រូបខ្ញុំ និងរដ្ឋាភិបាលកម្ពុជាកាន់តែមានការយល់គ្នាថែមទៀត ថាតើយើងម្នាក់ៗបានឃើញភារកិច្ចអ្វីខ្លះនៅចំពោះមុខយើង ដើម្បីបញ្ជាក់ឱ្យច្បាស់ពី

វិស័យណាខ្លះដែលបានឯកភាពគ្នារួចហើយ និងដើម្បីរកឱ្យឃើញបញ្ហាណាខ្លះដែលចាំបាច់ត្រូវបន្តដោះស្រាយនៅក្នុងពេលចរចាគ្នា នាថ្ងៃខាងមុខ។

១០- នៅក្នុងកថាខ័ណ្ឌទី ១ នៃសេចក្តីសំរេចចិត្តលេខ 57/228, មហាសន្និបាតអង្គការសហប្រជាជាតិបានផ្តល់អាណត្តិឱ្យខ្ញុំយ៉ាងជាក់លាក់ ដើម្បីធ្វើការចរចាសំរេចជាចុងក្រោយលើកិច្ចព្រមព្រៀង ដែលត្រូវស្របគ្នាជាមួយបទប្បញ្ញត្តិនៃសេចក្តីសំរេចចិត្តនោះ។ ខ្ញុំយល់ឃើញថាដើម្បីឱ្យស្របតាមលក្ខខណ្ឌនៃសេចក្តីសំរេចចិត្តនេះ កិច្ចព្រមព្រៀងណាមួយធ្វើឡើងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាត្រូវតែស្របតាមលក្ខខណ្ឌដូចខាងក្រោមនេះ :

(ក) កិច្ចព្រមព្រៀងត្រូវតែគោរព និងផ្តល់ប្រសិទ្ធិភាពជាក់ស្តែងដល់គោលការណ៍ដែលអង្គជំនុំជំរះវិសាមញ្ញជាតុលាការថ្នាក់ជាតិចិតក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ដែលត្រូវបានបង្កើតឡើង និងដំណើរការក្រោមជំនួយ[១] អន្តរជាតិ។

(ខ) កិច្ចព្រមព្រៀងត្រូវតែធានាថា អង្គជំនុំជំរះវិសាមញ្ញមានយុត្តាធិការផ្អែកតាមកម្មវត្ថុនៃករណីរឿងស្របគ្នាជាមួយយុត្តាធិការដែលមានចែងក្នុងច្បាប់កម្ពុជាស្តីពីការបង្កើតអង្គជំនុំជំរះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដើម្បីជំនុំជំរះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ (ច្បាប់) ហើយដែលច្បាប់នេះមានយុត្តាធិ-ការផ្ទាល់ទៅលើអ្នកដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងច្បាប់នោះ[២] ។

(គ) កិច្ចព្រមព្រៀងត្រូវចែងអំពីត្រូវមានសាលាឧទ្ធរណ៍មួយ នៅក្នុងអង្គជំនុំជំរះវិសាមញ្ញ[៣] ។

(ឃ) កិច្ចព្រមព្រៀងត្រូវធានាថាការចោទប្រកាន់ និងជំនុំជំរះនៅចំពោះមុខអង្គជំនុំជំរះវិសាមញ្ញត្រូវគោរព តាមបទដ្ឋានអន្តរជាតិដែលបានបង្កើតឡើងស្តីពីយុត្តិធម៌ ភាពត្រឹមត្រូវ និងនីតិវិធីត្រឹមត្រូវតាមច្បាប់ដូចមានចែងក្នុងមាត្រា ១៤ និងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[៤] ។

(ង) កិច្ចព្រមព្រៀងត្រូវធានាថា កិច្ចដំណើរការចោទប្រកាន់ និងកាត់សេចក្តីចំពោះមុខអង្គជំនុំជំរះវិសាមញ្ញគឺជាអង្គជំនុំជំរះដែលអាចជឿទុកចិត្តបានដែលស្របតាមបទដ្ឋានអន្តរជាតិដែលបានបង្កើតឡើងស្តីពីឯករាជ្យភាព និងភាពមិនលំអៀងរបស់តុលាការ ប្រសិទ្ធិភាព ភាពមិនលំអៀង និងភាពត្រឹមត្រូវនៃព្រះរាជអាជ្ញា និងសុចរិតភាពនៃដំណើរការតាមផ្លូវតុលាការ[៥] ។

(ច) កិច្ចព្រមព្រៀងត្រូវគ្រោងរចនាសម្ព័ន្ធឱ្យបានច្បាស់លាស់ ដើម្បីអាចបង្កើតអង្គជំនុំជំរះវិសាមញ្ញបានយ៉ាងឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន អាចចាប់ផ្តើមដំណើរការការងារបានភ្លាមៗ ហើយបន្ទាប់មកអាចប្រតិបត្តិការការងារបានប្រកបដោយនិរន្តរភាព និងចំណាយប្រកបដោយប្រសិទ្ធិភាព។ បើពុំដូច្នោះទេ ឆាប់ៗនេះនឹងត្រូវបាត់បង់[៦] ឱកាស

កាត់ទោសជនដែលទទួលខុសត្រូវចំពោះការរំលោភធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យជាពុំខានឡើយ។

(ឆ) ក្រោយពីលក្ខខណ្ឌជាក់ស្តែងទាំងប្រាំមួយចំណុចនេះ មហាសន្និបាតអង្គការសហប្រជាជាតិក៏បានដាក់ចេញនូវលក្ខខណ្ឌទីប្រាំពីរផងដែរ ដែលមានលក្ខណៈជានីតិវិធីច្រើនជាងៈ គឺមានន័យថាកិច្ចព្រមព្រៀងត្រូវផ្អែកលើការចរចាពីលើកមុនដែលបានធ្វើឡើងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា[៧]។

១១- ផ្អែកតាមខ្លឹមសារខាងលើនេះ ខ្ញុំយល់ឃើញថាការចរចាជាបន្តទៀត គួរផ្អែកតាមនេះ ដើម្បីចាត់ទុកជាចំណុចចាប់ផ្តើមនៃការចេញដំណើរ សេចក្តីព្រាងនៃកិច្ចព្រមព្រៀងដែលត្រូវបានយកមកពិភាក្សានៅក្នុងពេលចរចាកន្លងមកនេះរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាដែលបានមកដល់ទីបញ្ចប់ហើយកាលពីថ្ងៃទី ៨ កម្ភៈ ២០០២។

១២- នៅពេលជាមួយគ្នានេះ ខ្ញុំបានយល់ឃើញផងដែរថា មហាសន្និបាតអង្គការសហប្រជាជាតិបានប្រគល់ឱ្យខ្ញុំនូវអាណត្តិកិច្ចយ៉ាងច្បាស់លាស់ និងស្រពិចស្រពិលដើម្បីធ្វើការចរចាស្វែងរកការព្រមព្រៀងគ្នាមួយ ដែលត្រូវដាក់បញ្ចូលនូវការកែប្រែចំណុចមួយចំនួនក្នុងសេចក្តីព្រាងនេះ។

១៣- មានកត្តាពីរជាពិសេស បានបញ្ជាក់ប្រាប់ខ្ញុំច្បាស់អំពីទស្សនៈនោះ។ កត្តាទី ១ គឺសេចក្តីសំរេចចិត្តលេខ ៥៧/២២៥ របស់មហាសន្និបាតអង្គការសហប្រជាជាតិស្តីពីសភាពការណ៍សិទ្ធិមនុស្សនៅកម្ពុជា។ នៅក្នុងសេចក្តីសំរេចចិត្តនោះ ដែលបានអនុម័តនៅថ្ងៃតែមួយជាមួយសេចក្តីសំរេចចិត្តលេខ 57/228 នៃមហាសន្និបាតអង្គការសហប្រជាជាតិ "មហាសន្និបាតបានធ្វើការកត់សំគាល់ដោយសេចក្តីព្រួយបារម្ភចំពោះបញ្ហាដែលនៅតែបន្តកើតមាន ទាក់ទិននឹងនីតិរដ្ឋ និងការប្រព្រឹត្តទៅនៃតុលាការ [កម្ពុជា] ដែលបណ្តាលមកពីបញ្ហា (ក្នុងចំណោមបញ្ហាដទៃទៀត) អំពើពុករលួយ និងការជ្រៀតជ្រែកពីអង្គនីតិប្រតិបត្តិលើឯករាជ្យភាពរបស់តុលាការ[៨]"។ ខ្ញុំត្រូវតែយកចិត្តទុកដាក់ច្បាស់លាស់ចំពោះការរកឃើញរបស់មហាសន្និបាតអង្គការសហប្រជាជាតិ នៅពេលឈានចូលដល់ការអនុវត្តកថាខណ្ឌទី ៥ នៃសេចក្តីសំរេចចិត្តលេខ 57/228។ ជាពិសេស ខ្ញុំបានយល់ច្បាស់ថាបើសិនជាខ្ញុំត្រូវតែគោរពតាមលក្ខខណ្ឌនៃអាណត្តិកិច្ចដែលមហាសន្និបាតអង្គ-ការសហប្រជាជាតិបានប្រគល់ឱ្យខ្ញុំនោះ១ ខ្ញុំត្រូវតែពិនិត្យសេចក្តីព្រាងនៃកិច្ចព្រមព្រៀងដែលបានពិភាក្សាកន្លងមកឡើងវិញ ហើយបើសិនជាចាំបាច់ ស្នើឱ្យធ្វើការកែសម្រួលលើសេចក្តីព្រាងនោះ ដើម្បីធានាឱ្យភាពមិនលំអៀង និងឯករាជ្យ-ភាពរបស់អង្គជំនុំជំរះវិសាមញ្ញ ភាពស្អាតស្អំ និងភាពអាចជឿទុកចិត្តបាននៃកិច្ចដំណើរការរបស់តុលាការត្រូវបានធានាយ៉ាងពេញលេញ។

១៤-កត្តាទីពីរ គឺបទពិសោធន៍របស់ខ្ញុំក្នុងការចរចាកន្លងមកជាមួយរដ្ឋាភិបាលកម្ពុជា។ ក្នុងការចរចាទាំងអស់កន្លងមករដ្ឋាភិបាលកម្ពុជាបានបង្ហាញពីកង្វះភាពប្រញាប់ប្រញាល់ គួបផ្សំនឹងកង្វះការប្តេជ្ញាចិត្តដ៏សកម្ម និងជាវិជ្ជមានចំពោះកិច្ចដំណើរការដែលអាចមានសារសំខាន់ នៅពេលដែលឈានដល់ការអនុវត្តកិច្ចព្រមព្រៀងណាមួយ និងផ្តល់ការបង្កើតអង្គ

ជំនុំជំរះវិសាមញ្ញធ្វើឱ្យអង្គជំនុំជំរះនេះបានដំណើរការ និងចានាកិច្ចប្រតិបត្តិការការងាររបស់ខ្លួនបានប្រកបដោយនីរន្តរភាព។ ជាការពិតណាស់ គឺកង្វះការប្តេជ្ញាចិត្តពីភាគីរដ្ឋាភិបាល នេះហើយដែលជាហេតុផលដ៏ចម្បងដែលនាំឱ្យខ្ញុំសំរេចចិត្តកាលថ្ងៃទី ៨ កុម្ភៈ ២០០២ ថាមិនត្រូវបន្តកិច្ចចរចាពីមុនមកតទៅទៀតទេ។ តាមធម្មតា ខ្ញុំមិនអាចធ្វើមិនដឹងមិនឮចំពោះបទពិសោធន៍នេះទេ នៅពេលដែលសំរេចថាត្រូវផ្តល់ប្រសិទ្ធភាពចំពោះបំណងប្រាថ្នារបស់អគ្គលេខាធិការដែលមានចែងនៅក្នុងកថាខណ្ឌទី១,៩ និងទី ១០ នៃសេចក្តីសំរេចចិត្តលេខ 57/228 ថាកិច្ចព្រមព្រៀងណាមួយទាក់ទងនឹងអង្គជំនុំជំរះវិសាមញ្ញគួរសំរួលដល់ការបង្កើតអង្គជំនុំជំរះនេះឱ្យបានទាន់ពេលវេលា និងដំណើរការការងាររបស់ខ្លួនបានឆាប់រហ័ស និងមានប្រសិទ្ធភាព។

១៥-សេចក្តីព្រាងនៃកិច្ចព្រមព្រៀងដែលបានពិភាក្សា ក្នុងអំឡុងពេលនៃកិច្ចពិភាក្សាកន្លងមកបានចែងពីការរៀបចំ និងពីរចនាសម្ព័ន្ធរបស់អង្គជំនុំជំរះវិសាមញ្ញ ដែលត្រូវការរៀបចំក្នុងលក្ខណៈមួយដែលមានភាពស្មុគស្មាញបំផុតហើយដែលបើកឱ្យមានលទ្ធភាពក្នុងវិសាលភាពដ៏ធំទូលាយក្នុងការធ្វើឱ្យរាំងស្ទះ និងការអូសបន្លាយពេលវេលានៃកិច្ចដំណើររឿងក្តីរបស់ខ្លួន។ ទោះបីជាស្ថិតនៅឆ្ងាយពីឧត្តមគតិក៏ដោយក៏ រចនាសម្ព័ន្ធ និងការរៀបចំនៅតែអាចដំណើរការបានជាដដែលបើសិនជារដ្ឋាភិបាលកម្ពុជាមានការប្តេជ្ញាចិត្តឱ្យបានពេញលេញក្នុងការបង្កើតអង្គជំនុំជំរះវិសាមញ្ញ និងធ្វើឱ្យអង្គជំនុំជំរះនេះដំណើរការ។ កន្លងមកធ្លាប់បានឃើញជាក់ស្តែងហើយថា ទោះបីជាកិច្ចចចារកន្លងមកបានបន្តក៏ដោយក៏ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលមិនអាចយកជាការពិតប្រាកដបានទេ។ ចិត្តក្នុងកាលៈទេសៈនេះ ខ្ញុំបានយល់ច្បាស់ថា រចនាសម្ព័ន្ធ និងការរៀបចំនៃអង្គជំនុំជំរះវិសាមញ្ញត្រូវតែធ្វើឱ្យបានសាមញ្ញដើម្បីងាយស្រួល ដល់ការបង្កើតអង្គនេះបានឆាប់រហ័ស និងលុបបំបាត់រាល់ឧបសគ្គដែលរាំងស្ទះដល់កិច្ចប្រតិបត្តិការរបស់ខ្លួនប្រកបដោយ ភាពឆាប់រហ័ស និងមានប្រសិទ្ធភាព។ បើមិនដូច្នេះទេ នឹងអាចបាត់បង់ឱកាសក្នុងការនាំខ្លួនជនដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនេះយកមកកាត់ទោស។ ហើយទិសដៅទាំងមូលនៃសេចក្តីសំរេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិនឹងត្រូវទទួលបរាជ័យជាពុំខានឡើយ។

១៦- អាស្រ័យហេតុដូចខាងលើនេះ ខ្ញុំបានដាក់ជូននូវសំណើរដូចខាងក្រោមនេះ នៅក្នុងសម័យប្រជុំស្រាវជ្រាវ ដែលប្រព្រឹត្តទៅនៅទីក្រុងញូវយ៉ក :

(ក) នៅក្នុងកិច្ចព្រមព្រៀងគួរមានចែងអំពីវិធានអំពីថា តើអង្គជំនុំជំរះវិសាមញ្ញត្រូវមានការរៀបចំ និងរចនាសម្ព័ន្ធយ៉ាងដូចម្តេចខ្លះ ហើយតើត្រូវដំណើរការការងាររបស់ខ្លួនយ៉ាងដូម្តេច? ប្រសិនបើអង្គជំនុំជំរះនេះត្រូវទទួលជំនួយអន្តរ-ជាតិពីអង្គការសហប្រជាជាតិនោះ។ ហើយថ្ងៃក្រោយមកទៀត បើសិនជារដ្ឋាភិបាលត្រូវធ្វើការកែប្រែរចនាសម្ព័ន្ធ និងការរៀបចំនៃអង្គជំនុំជំរះវិសាមញ្ញខុសពីកិច្ចព្រមព្រៀង ឬបើសិនជាមានការបង្កឡើងឱ្យការរៀបចំ និងរចនាសម្ព័ន្ធដំណើរការបែបណាមួយ ដែលខុសពីលក្ខខណ្ឌនៃកិច្ចព្រមព្រៀង នោះអង្គការសហប្រជាជាតិមានសិទ្ធិនឹងបញ្ឈប់ការផ្តល់ជំនួយដែលស្ថិតក្រោមកិច្ចព្រមព្រៀងនេះ។

(ខ) រចនាសម្ព័ន្ធនៃអង្គជំនុំជំរះវិសាមញ្ញ ដូចដែលបានរំពឹងទុកនៅក្នុងអំឡុងពេលនៃកិច្ចចរចាកន្លងមកនេះ គួររៀបចំធ្វើឱ្យមានលក្ខណៈសាមញ្ញលើទិដ្ឋភាពមួយចំនួន។ ធ្វើដូចនេះ នឹងអាចធ្វើឱ្យមានលទ្ធភាពដើម្បីបង្កើតអង្គជំនុំជំរះបានឆាប់រហ័សតាមដែលអាចធ្វើទៅបានដើម្បីឱ្យអង្គជំនុំជំរះនេះអាចចាប់ផ្តើមដំណើរការការងារភ្លាមៗ និងធ្វើឱ្យកិច្ចប្រតិបត្តិការរបស់ខ្លួនប្រកបដោយនិរន្តរភាព និងការចំណាយប្រកបដោយប្រសិទ្ធិភាព។ វាក៏អាចបង្កើនការទុកចិត្តចំពោះអង្គជំនុំជំរះដែរ ដោយការបន្ថយឱ្យនៅទាបជាអប្បបរិមានូវវិសាលភាពដែលធ្វើឱ្យអូសបន្លាយពេលវេលានៃការស៊ើបអង្កេត ចោទប្រកាន់ និងជំនុំជំរះ។ ផ្អែកតាមខ្លឹមសារនេះ នៅក្នុងកិច្ចព្រមព្រៀងគួរបានចែងអំពីអង្គជំនុំជំរះវិសាមញ្ញ និងស្ថាប័នពាក់ព័ន្ធរបស់ខ្លួនដែលត្រូវរៀបចំរចនាសម្ព័ន្ធដូចខាងក្រោមនេះ :

- អង្គជំនុំជំរះវិសាមញ្ញគួរមានរចនាសម្ព័ន្ធដ៏សាមញ្ញមួយដែលមានត្រឹមតែពីរថ្នាក់ ដែលរួមមានអង្គជំនុំជំរះវិសាមញ្ញសាលាដំបូងនិងអង្គជំនុំជំរះវិសាមញ្ញសាលាឧទ្ធរណ៍។ សេចក្តីព្រាងដែលបានពិភាក្សាកន្លងមកបានចែងអំពីអង្គជំនុំជំរះដែលមានលក្ខណៈស្មុគ្រស្មាញជាងនេះ ដោយកំណត់យករចនាសម្ព័ន្ធមួយមានបីថ្នាក់ដែលរួមមានអង្គជំនុំជំរះសាលាដំបូង និងអង្គជំនុំជំរះសាលាឧទ្ធរណ៍ និងអង្គជំនុំជំរះតុលាការកំពូល។
- អង្គជំនុំជំរះវិសាមញ្ញសាលាដំបូងគួរមានសមាសភាពចៅក្រមចំនួនបីរូប ហើយអង្គជំនុំជំរះវិសាមញ្ញសាលាឧទ្ធរណ៍មានចៅក្រមចំនួនប្រាំរូប។ រីឯនៅក្នុង សេចក្តីព្រាងចាស់បានចែងកំណត់ចំនួនចៅក្រមប្រាំរូបសំរាប់អង្គជំនុំជំរះវិសាមញ្ញសាលាដំបូង និងចៅក្រមប្រាំពីររូបសំរាប់អង្គជំនុំជំរះសាលាឧទ្ធរណ៍។
- គួរមានព្រះរាជអាជ្ញាមួយរូប និងចៅក្រមស៊ើបអង្កេតមួយរូបបានហើយ។ នៅក្នុងសេចក្តីព្រាងចាស់បានចែងកំណត់ចំនួនសហព្រះរាជអាជ្ញាពីររូប និងសហចៅក្រមស៊ើបអង្កេតពីររូប។
- ហេតុដូច្នេះ មិនគួរចាំបាច់បង្កើតឱ្យមានយន្តការមួយសំរាប់ដោះស្រាយការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញាឬរវាងសហចៅក្រមស៊ើបអង្កេតទេ។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជំរះ ដែលពីដំបូងគេគ្រោងបង្កើតឡើងក្នុងគោលបំណងដើម្បីដោះស្រាយបញ្ហានោះ គឺមិនចាំបាច់មានទេ។
- ភាសាដែលប្រើប្រាស់ជាផ្លូវការក្នុងការងាររបស់អង្គជំនុំជំរះវិសាមញ្ញគួរធ្វើជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង។ មិនគួរយកភាសាណាផ្សេងទៀត សំរាប់ប្រើប្រាស់ជាផ្លូវការក្នុងការងារនេះទេ។

(គ) ដើម្បីធានាភាពមិនលំអៀង ឯករាជ្យភាព និងការអាចជឿទុកចិត្តបានក្នុងការស៊ើបអង្កេត ការចោទប្រកាន់ ការជំនុំជំរះ គួរធ្វើការកែសំរួលក្នុងសេចក្តីព្រាងនៃកិច្ចព្រមព្រៀងដែលបានពិភាក្សា នៅក្នុងអំឡុងនៃកិច្ចចរចានាពេលកន្លងមកលើចំណុចមួយចំនួនដូចខាងក្រោមនេះ :

- ចំនួនភាគច្រើននៃចៅក្រម ទាំងនៅក្នុងអង្គជំនុំជំរះវិសាមញ្ញសាលាដំបូង ទាំងនៅក្នុងអង្គជំនុំជំរះវិសាមញ្ញសាលា-ឧទ្ធរណ៍ គួរតែជាចៅក្រមបរទេស។ នៅក្នុងសេចក្តីព្រាងចាស់បានចែងកំណត់ចៅក្រមកម្ពុជាមានចំនួនភាគច្រើននៅក្នុងអង្គជំនុំជំរះ។

- សេចក្តីសំរេចនៃអង្គជំនុំជំរះវិសាមញ្ញសាលាដំបូងគួរតែធ្វើឡើងដោយសំលេងភាគច្រើនដាច់ខាត។ នៅក្នុងសេចក្តីព្រាងចាស់បានចែងថា សេចក្តីសំរេចត្រូវធ្វើឡើងដោយ "សំលេងភាគច្រើនលើសលុប" ដែលក្នុងនោះមានសំលេងគាំទ្រដោយចៅក្រមភាគច្រើនដាច់ខាត បូកមួយ។
- ទាំងព្រះរាជអាជ្ញា ទាំងចៅក្រមស៊ើបអង្កេតគួរតែជាបុគ្គលិកបរទេស។

(ឃ) ដើម្បីធានាឱ្យស្របតាមបទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌ ភាពត្រឹមត្រូវ និងនីតិវិធីត្រឹមត្រូវតាមច្បាប់ កិច្ចព្រមព្រៀងគួរចែងបទប្បញ្ញត្តិដូចខាងក្រោម :

- អង្គជំនុំជំរះវិសាមញ្ញគួរប្រើប្រាស់យុត្តាធិការរបស់ខ្លួន ស្របតាមបទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌ ភាពត្រឹមត្រូវ និងនីតិវិធីត្រឹមត្រូវតាមច្បាប់ ដូចមានចែងនៅក្នុងមាត្រា ១៤ និងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។
- សិទ្ធិរបស់ជនជាប់ចោទដែលមានចែងនៅក្នុងមាត្រាទាំងនោះ នៃកតិកាសញ្ញាគួរតែគោរពនៅគ្រប់ពេលវេលា ដោយរួមទាំងសិទ្ធិមានមេធាវីការពារ តាមការជ្រើសរើសរបស់ខ្លួន។
- គួរតែគោរពយ៉ាងពេញលេញបំផុតចំពោះសិទ្ធិរបស់ជនជាប់ចោទ ដែលត្រូវទទួលបាននូវការជំនុំជំរះក្តីប្រកបដោយយុត្តិធម៌ និងសវនាការដែលត្រូវធ្វើជាសាធារណៈ។ តំណាងនៃរដ្ឋជាសមាជិក លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ និងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិព្រមទាំងប្រព័ន្ធផ្សព្វផ្សាយពត៌មានអាចត្រូវតែមានសិទ្ធិអាចចូលរួមសង្កេតការណ៍នៅក្នុងកិច្ចដំណើរការជំនុំជំរះក្តីបានគ្រប់ពេលវេលាទាំងអស់។
- ការអនុញ្ញាតនេះ គួរត្រូវបានបដិសេធតែនៅក្នុងករណីណាដែលមានការចាំបាច់បំផុតតែប៉ុណ្ណោះ តាមមតិរបស់អង្គជំនុំជំរះពាក់ព័ន្ធ និងបើសិនជា សវនាការជាសាធារណៈនោះអាចនឹងនាំឱ្យខូចប្រយោជន៍ក្នុងការស្វែងរកយុត្តិធម៌។
- នីតិវិធីដែលអង្គជំនុំជំរះវិសាមញ្ញត្រូវអនុវត្តតាមគួរតែជានីតិវិធីដែលមានចែងនៅក្នុងច្បាប់កម្ពុជា។ ទន្ទឹមនឹងនេះ នៅពេលដែលច្បាប់កម្ពុជាមិនបានចែងពីបញ្ហាអ្វីមួយជាពិសេស ឬនៅពេលដែលមានភាពមិនច្បាស់លាស់ទាក់ទិននឹងការបកស្រាយ ឬការអនុវត្តវិធានពាក់ព័ន្ធណាមួយនៃច្បាប់កម្ពុជា ឬនៅពេលដែលមានបញ្ហាស្តីពីភាពមិនស្របគ្នារវាង វិធាននោះជាមួយបទដ្ឋានអន្តរជាតិ អង្គជំនុំជំរះវិសាមញ្ញអាចនឹងយកវិធានអន្តរជាតិដើម្បីធ្វើជាគោលការណ៍ណែនាំ។
- គួរផ្តល់ឱ្យអង្គជំនុំជំរះវិសាមញ្ញមានសិទ្ធិក្នុងការសំរេចថាតើការលើកលែងទោសដែលបានផ្តល់ឱ្យដល់បុគ្គលមួយរូបកាលពីថ្ងៃទី ១៤ កញ្ញា ១៩៩៦ អាចប្រើប្រាស់សំរាប់ជាការរាំងខ្ទប់ដល់ការចោទប្រកាន់ ឬការផ្តន្ទាទោសគាត់ពីបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងសម័យកាលនៃការគ្រប់គ្រងអំណាចរបស់គាត់បានដែរឬទេ។

(ង) បើតាមដឹងកន្លងមក យុត្តាធិការនៃអង្គជំនុំជំរះវិសាមញ្ញក្នុងកិច្ចព្រមព្រៀងគួរចែងដូចខាងក្រោមនេះ :

- អង្គជំនុំជំរះវិសាមញ្ញគួរមានយុត្តាធិការផ្តែកតាមកម្មវត្ថុនៃករណីរឿង តាមប្រភេទនៃបទល្មើសដែលមានចែងនៅក្នុងជំពូកទី II នៃច្បាប់ជាតិកម្ពុជា ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី ១០ សីហា ២០០១។
- អង្គជំនុំជំរះវិសាមញ្ញគួរមានយុត្តាធិការចំពោះបុគ្គលមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ និងជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលអង្គជំនុំជំរះវិសាមញ្ញមានយុត្តាធិការផ្អែកតាមកម្មវត្ថុនៃករណីរឿងនោះ។

(ច) កិច្ចព្រមព្រៀងគួរមានចែងអំពីការរៀបចំសំរួលលើបញ្ហាផ្តល់ថវិកា និងជំនួយឧបត្ថម្ភដល់អង្គជំនុំជំរះវិសាមញ្ញ។ ជាពិសេស កិច្ចព្រមព្រៀងនេះគួរចែងដូចខាងក្រោមនេះ :

- ការទទួលខុសត្រូវចំពោះការចំណាយលើប្រាក់បៀវត្ស និងបរិលាភនៃបុគ្គលិកបរទេសគួរជាបន្ទុករបស់អង្គការសហ-ប្រជាជាតិ។
- ការទទួលខុសត្រូវចំពោះការចំណាយលើប្រាក់បៀវត្ស និងបរិលាភនៃបុគ្គលិកកម្ពុជាជាបន្ទុករបស់រដ្ឋាភិបាលកម្ពុជា។
- ការទទួលខុសត្រូវចំពោះការចំណាយលើកិច្ចដំណើរការការងាររបស់អង្គជំនុំជំរះវិសាមញ្ញគួរតែជាបន្ទុករបស់អង្គការសហប្រជាជាតិ។

១៧- នៅក្នុងសម័យប្រជុំដើម្បីសិក្សាស្រាវជ្រាវនៅទីក្រុងញូវយ៉ក ក្រុមកម្ពុជាបានបញ្ជាក់ថា លើកលែងតែមួយចំណុច (ដូចបានកត់សំគាល់ខាងក្រោម) ចេញគឺគេបដិសេធលើសំណើទាំងស្រុងរបស់ខ្ញុំ ដូចដែលមានចែងនៅក្នុងចំណុច (ក) និងចំណុច (ខ) នៃកថាខណ្ឌខាងមុខ ដែលស្តីពីរចនាសម្ព័ន្ធ និងការចាត់តាំងនៃអង្គជំនុំជំរះវិសាមញ្ញ។ គណៈប្រតិភូកម្ពុជាបានកត់សំគាល់ថា សំណើទាំងនោះមុខជាធ្វើឱ្យមានការកែប្រែនៅក្នុងសេចក្តីព្រាងនៃកិច្ចព្រមព្រៀងដែលបានពិភាក្សារួចមកហើយនៅក្នុងកិច្ចចរចាកន្លងមកជាពុំខាន។ ខ្ញុំជឿជាក់ថាអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាបានឈានដល់ការព្រមព្រៀងគ្នាលើបញ្ហាទាំងនោះរួចហើយ។ ហើយក៏ជឿជាក់ដែរថា សេចក្តីសំរេចចិត្តនៃអង្គការសហប្រជាជាតិបានតម្រូវថា ចំណុចណាដែលបានព្រមព្រៀងគ្នារួចហើយកាលពីពេលចរចាកន្លងមកនេះ ត្រូវតែគោរពជាដដែលនៅក្នុងពេលបន្តការចរចាឡើងវិញ។ គណៈប្រតិភូកម្ពុជាក៏បានបញ្ជាក់បន្ថែមទៀតថា ថាសំណើដែលមានបញ្ហា គឺផ្ទុយនឹងច្បាប់កម្ពុជាដែលបានប្រកាសឱ្យប្រើ ចុះថ្ងៃទី ១០ សីហា ២០០១ ហើយរដ្ឋាភិបាលមិនត្រៀមលក្ខណៈដើម្បីពិនិត្យពិចារណាលើសំណើទាំងឡាយណាដែលធ្វើឱ្យមានការកែប្រែច្បាប់នោះទេ។ អាចលើកលែងបានតែអ្វីដែលបានចែងនៅក្នុងកថា-ខណ្ឌទី ៤ (ខ) នៃសេចក្តីសំរេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិតែប៉ុណ្ណោះគឺ ការកាត់បន្ថយចំនួននៃអង្គជំនុំជំរះវិសាមញ្ញពីបីថ្នាក់មកនៅត្រឹមតែពីរថ្នាក់វិញ។ គណៈប្រតិភូកម្ពុជាបានបញ្ជាក់ថែមទៀតថា តាមទស្សនៈរបស់ខ្លួនមិនចាំបាច់ធ្វើការកែប្រែរចនាសម្ព័ន្ធ និងការចាត់តាំងនៃអង្គជំនុំជំរះវិសាមញ្ញដូចដែលមានចែងនៅក្នុងច្បាប់របស់ខ្លួន ចុះថ្ងៃទី ១០ សីហា ២០០១ ទេ ដើម្បីធានាឱ្យកិច្ចដំណើរការរឿងក្តីនៅចំពោះអង្គជំនុំជំរះវិសាមញ្ញនេះអាចឱ្យជឿទុកចិត្តបាន។ កិច្ចការនោះអាចធ្វើបានដោយការធានាការអនុវត្តបានត្រឹមត្រូវតាមបទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌ ភាពត្រឹមត្រូវ

និងនីតិវិធីត្រឹមត្រូវតាមច្បាប់ ដូចមានចែងក្នុងមាត្រា ១៤ និងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។

**ខ- ភ្នំពេញ : ខែ មីនា ឆ្នាំ ២០០៣**

១៨. កាលពីនៅថ្ងៃទី ១៣ កុម្ភៈ ២០០៣ តំណាងអចិន្ត្រៃយ៍នៃប្រទេសកម្ពុជាប្រចាំនៅអង្គការសហប្រជាជាតិបានប្រគល់ឱ្យនូវលិខិតមួយច្បាប់ពីនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលចុះថ្ងៃទី ១៣ មករា ២០០៣។ ក្នុងលិខិតនោះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានស្នើខ្ញុំឱ្យបញ្ជូនក្រុមការងារមួយក្រុមមកទីក្រុងភ្នំពេញឱ្យបានយ៉ាងឆាប់ៗតាមដែលអាចធ្វើទៅបាន។ ខ្ញុំក៏បានសរសេរលិខិតឆ្លើយតបមកវិញនៅថ្ងៃបន្ទាប់មក ដោយទទួលយល់ព្រមតាមការស្នើសុំ ហើយបានជូនដំណឹងទៅគាត់ពីកាលបរិច្ឆេទ ដែលក្រុមរបស់ខ្ញុំនឹងធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញ។ នៅថ្ងៃទី ១៨ កុម្ភៈ ២០០៣ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសរសេរលិខិតជូនដំណឹងមកខ្ញុំវិញថា នៅថ្ងៃបន្ទាប់ពីកាលបរិច្ឆេទដែលខ្ញុំបានបញ្ជាក់នៅក្នុងលិខិតរបស់ខ្ញុំ រដ្ឋាភិបាលរបស់លោកមានសេចក្តីរីករាយនឹងទទួលស្វាគមន៍ចំពោះក្រុមរបស់ខ្ញុំ។

១៩. អាស្រ័យហេតុនេះ ក្រុមរបស់អង្គការសហប្រជាជាតិមួយក្រុមតូចដឹកនាំដោយទីប្រឹក្សាច្បាប់ លោក ហាន់ កូរ៉ែល បានមកធ្វើទស្សនកិច្ចនៅទីក្រុងភ្នំពេញ ចាប់ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ១៧ មីនា ២០០៣។ អមដំណើរលោក ហាន់ កូរ៉ែល មានលោក ឡាម៉ិន ស៊ីស៊ី នាយកទទួលបន្ទុកកិច្ចការច្បាប់ សិទ្ធិមនុស្ស និងការចាត់តាំងពិសេស ការិយាល័យប្រតិបត្តិនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក សារុន វ៉ាន់បឺលី ជំនួយការពិសេសនៃអ្នកត្រួតពិនិត្យ ការិយាល័យអ្នកត្រួតពិនិត្យ ការិយាល័យផែនការកម្មវិធី ថវិកា និងគណនេយ្យ លោក ដេវីត ហាត់ឈីនសិន មន្ត្រីច្បាប់នៃការិយាល័យទីប្រឹក្សាច្បាប់ ការិយាល័យកិច្ចការច្បាប់ លោក អេឡែន អាល់វ៉ាឌី មន្ត្រីទទួលបន្ទុកកិច្ចការនយោបាយ តំបន់អាស៊ីប៉ាស៊ី-ហ្វិច នាយកដ្ឋានកិច្ចការច្បាប់ និងហ្គោរ៉ូ អូណូជីម៉ា មន្ត្រីសិទ្ធិមនុស្ស ការិយាល័យប្រចាំទីក្រុងញូវយ៉ក ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ។ ក្នុងអំឡុងពេលទស្សនកិច្ចរបស់ខ្លួនរយៈពេលប្រាំថ្ងៃ ក្រុមនេះបានធ្វើការចរចាជាលំអិតទៅលើបញ្ហាដែលនៅសេសសល់មួយចំនួន ដែលបានសំគាល់ឃើញកាលពីមានកិច្ចប្រជុំដើម្បីស្រាវជ្រាវដែលបានធ្វើឡើងនៅទីក្រុងញូវយ៉កនាពេលកន្លងមកនេះ។ ក្រុមការងារក៏បានធ្វើការប៉ាន់ស្មានពីភាពគ្រប់គ្រាន់ នៃទីតាំងដែលអាចប្រើប្រាស់សំរាប់អង្គជំនុំជំរះវិសាមញ្ញ និងស្ថាប័នពាក់ព័ន្ធរបស់ខ្លួន និងបានធ្វើការពិភាក្សាលើបញ្ហាជាក់ស្តែងមួយចំនួនជាមួយមន្ត្រីជាន់ខ្ពស់នៃរដ្ឋាភិបាលកម្ពុជា ស្តីពីសេចក្តីត្រូវការសំរាប់អង្គជំនុំជំរះវិសាមញ្ញទាក់ទងនឹងបញ្ហាថវិកា គ្រឿងបរិក្ខារ សេវា និងបុគ្គលិក។

២០.ខ្ញុំបានសំគាល់ឃើញយ៉ាងច្បាស់ នៅក្នុងអំឡុងពេលទស្សនៈកិច្ចនៃក្រុមរបស់ខ្ញុំទៅកាន់ទីក្រុងភ្នំពេញថា រដ្ឋាភិបាលកម្ពុជាមិនបានត្រៀមលក្ខណៈដើម្បីពិនិត្យពិចារណាលើសំណើ ដែលតម្រូវឱ្យខ្លួនធ្វើការកែប្រែលើចំណុចខ្លះនៃបទប្បញ្ញត្តិទាំងនោះនៃច្បាប់ជាតិរបស់ខ្លួន ដែលចែងពីថាតើអង្គជំនុំជំរះវិសាមញ្ញត្រូវរៀបចំរចនាសម្ព័ន្ធ និងការចាត់តាំងបែបណា (ដោយលើកលែងតែលក្ខខ័ណ្ឌចែងអំពីការបន្ថយចំនួនថ្នាក់តុលាការពីបីថ្នាក់មកនៅត្រឹមតែពីរថ្នាក់វិញប៉ុណ្ណោះ) ។

២១. អ្វីដែលកាន់តែច្បាស់ជាងនេះទៀតនោះគឺ ដោយរដ្ឋជាសមាជិកមួយចំនួនដែលកំពុងតាមដានយ៉ាងជិតដល់អំពីការបន្តចរចាឡើងវិញនេះ បានធ្វើឱ្យខ្ញុំយល់ច្បាស់ថា ពួកគេមិនចង់ឱ្យខ្ញុំស្នើសុំឱ្យធ្វើការកែប្រែណាមួយនៅក្នុងរចនាសម្ព័ន្ធ និងចាត់តាំងនៃអង្គជំនុំជំរះវិសាមញ្ញដែលបានពិនិត្យពិចារណា នៅក្នុងអំឡុងពេលនៃការចរចាកាលពីលើកមុននោះទេ។ រដ្ឋាភិបាលកម្ពុជាបានដឹង យ៉ាងច្បាស់ថា ជំហរនេះត្រូវបានទាក់ទងមកខ្ញុំ ហើយត្រូវបានចាត់វិធានការទៅតាមនោះ។

២២. ថ្វីបើមានជំហរនេះក៏ដោយ ខ្ញុំបានសំរេចចិត្តថាត្រូវតែខិតខំប្រឹងប្រែងជាចុងក្រោយដើម្បីពង្រឹងតួនាទីនៃសមាស-ភាពខាងបរទេសនៅគ្រប់ដំណាលនៃការស៊ើបអង្កេត និងការចោទប្រកាន់ ហើយទន្ទឹមនឹងនេះ ដើម្បីធ្វើឱ្យដំណាក់កាលនៃកិច្ចដំណើរការទាំងនោះមានភាពសាមញ្ញដោយមិនចាំបាច់មានអង្គបុរេជំនុំជំរះទេ។ តាមការសំរេចចិត្តខាងលើនេះ ខ្ញុំបានណែនាំដល់ក្រុមរបស់ខ្ញុំឱ្យលើកឡើងសំណើថា ក្នុងករណីបើមានការខ្វែងគំនិតគ្នា រវាងសហចៅក្រមស៊ើបអង្កេតកម្ពុជា និងសហចៅក្រមស៊ើបអង្កេតបរទេសទាក់ទិននឹងការស៊ើបអង្កេតរបស់តុលាការ យោបល់របស់សហចៅក្រមស៊ើបអង្កេតបរទេសគួរតែជាសេចក្តីសំរេចដែលមានឧត្តមានុភាព។ ហើយខ្ញុំក៏បានធ្វើសំណើស្រដៀងគ្នានេះដែរ ទាក់ទងនឹងសហព្រះរាជអាជ្ញា។ ទោះជាយ៉ាងណាក្តី ប្រតិកម្មរបស់គណៈប្រតិភូកម្ពុជាចំពោះសំណើទាំងនេះ នៅតែអវិជ្ជមានដដែល។ អាស្រ័យហេតុនេះ ក្រុមរបស់ខ្ញុំក៏បានធ្វើការសន្និដ្ឋានយោបល់ថា មិនអាចមានលទ្ធភាពរៀបចំជាអត្ថបទដែលអាចធ្វើឱ្យគណៈប្រតិភូកម្ពុជាទទួលយកបាន ដែលរួមបញ្ចូលនូវបញ្ញត្តិស្របតាមអ្វីដែលបានគិតទុកនោះទេ។

២៣. បន្ទាប់មកខ្ញុំបានដឹងច្បាស់ថា គឺមានតែកិច្ចព្រមព្រៀងមួយប៉ុណ្ណោះ ដែលអាចយកមកធ្វើការចរចារជាមួយរដ្ឋាភិ-បាលបាននោះគឺ កិច្ចព្រមព្រៀងដែលបានយល់ព្រមទទួលយកតាមរចនាសម្ព័ន្ធ និងការចាត់តាំងនៃអង្គជំនុំជំរះវិសាមញ្ញដូចដែលមានចែងនៅក្នុងច្បាប់កម្ពុជា ចុះថ្ងៃទី ១០ សីហា ២០០១។ ហេតុដូចនេះ ក្រុមរបស់ខ្ញុំក៏បានបន្តចរចាជាមួយរដ្ឋាភិបាលលើបញ្ញត្តិសេចក្តីព្រាងនៃកិច្ចព្រមព្រៀងដែលស្តីពីរចនាសម្ព័ន្ធ ការចាត់តាំង និងការប្រព្រឹត្តទៅនៃអង្គជំនុំជំរះវិសាមញ្ញដែលបញ្ញត្តិទាំងនោះគឺបានផ្អែកតាមបញ្ញត្តិពាក់ព័ន្ធនៅក្នុងច្បាប់កម្ពុជា លើកលែងតែចំនួនថ្នាក់នៃអង្គជំនុំជំរះវិសាមញ្ញដែលត្រូវកាត់បន្ថយពីបីថ្នាក់មកនៅត្រឹមតែពីរថ្នាក់វិញ។ ផ្អែកលើមូលដ្ឋាននេះ - គឺមានតែមូលដ្ឋានមួយនេះប៉ុណ្ណោះ - ដែលបង្ហាញឱ្យខ្ញុំឃើញថា ខ្ញុំអាចមានលទ្ធភាពដើម្បីរៀបចំចងក្រងជាមួយរដ្ឋាភិបាលកម្ពុជានូវអត្ថបទសេចក្តីព្រាងនៃកិច្ចព្រមព្រៀងដោយលំអិតបាន។ អត្ថបទសេចក្តីព្រាងនៃកិច្ចព្រមព្រៀងនេះមាននៅក្នុងឧបសម្ព័ន្ធនៃរបាយការណ៍នេះ។

២៤. នៅក្នុងអត្ថបទនោះមានចែងអំពីចំនួននៃសមាសភាពជាវិជ្ជមាន។ ជាពិសេស មានការកែលំអលើផ្នែកសំខាន់ៗមួយចំនួនទៅលើអត្ថបទដែលបានពិភាក្សារួចហើយនៅក្នុងអំឡុងពេលចរចាកន្លងមក។

២៥. ទីមួយទាក់ទងនឹងតួនាទីរបស់សេចក្តីព្រាងនៃកិច្ចព្រមព្រៀងខ្លួនឯងផ្ទាល់។ អត្ថបទនៃសេចក្តីព្រាងកិច្ចព្រមព្រៀងដែលមានខ្លឹមសារដូចស្នើជូននៅពេលនេះ បើសិនជាចូលជាធរមាន នោះមុខជានឹងក្លាយទៅជាកិច្ចព្រមព្រៀងមួយជា

អន្តរជាតិរវាងអង្គការសហប្រជាជាតិ និងកម្ពុជាដែលនឹងត្រូវយកទៅអនុវត្តស្របតាមសេចក្តីតម្រូវនៃច្បាប់ស្តីពីសន្ធិសញ្ញាជាពុំខានឡើយ។ ចិតនៅចំកណ្តាលគេនោះគឺ គោលការណ៍ដែលមានចែងនៅក្នុងមាត្រា ២៦ និងមាត្រា ២៧ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់ស្តីពីសន្ធិសញ្ញា : ដែលក្នុងនោះគូភាគីទាំងឡាយត្រូវតែអនុវត្តសន្ធិសញ្ញានេះដោយសុទ្ធចិត្ត (Pacta sunt servanda) ហើយគូរភាគីមិនអាចយកបញ្ញត្តិច្បាប់ក្នុងស្រុករបស់ខ្លួន មកប្រើជាសំអាងនៅក្នុងករណីដែលខ្លួនខកខានមិនបានអនុវត្តតាមសន្ធិសញ្ញាបានឡើយ។ សេចក្តីព្រាងនៃកិច្ចព្រមព្រៀងបានចែងទៀតថា កិច្ចព្រមព្រៀងនេះនឹងត្រូវប្រើប្រាស់ធ្វើជាច្បាប់ដែរនៅក្នុងប្រទេសកម្ពុជា។ ដោយផ្អែកតាមបទបញ្ញត្តិនេះ ប្រទេសកម្ពុជាមានកាតព្វកិច្ចត្រូវធានាថា ច្បាប់ជាតិរបស់ខ្លួនត្រូវតែធ្វើឱ្យបានស្របជាមួយនឹងកិច្ចព្រមព្រៀងនេះ។ គឺក្នុងករណីបើច្បាប់ជាតិមិនស្របនឹងសេចក្តីព្រាងនៃកិច្ចព្រមព្រៀង ត្រូវតែធ្វើវិសោធនកម្មដើម្បីឱ្យច្បាប់ជាតិស្របគ្នានឹងសេចក្តីព្រាងនៃកិច្ចព្រមព្រៀងនេះ។ បន្ទាប់មកទៀត កម្ពុជាមិនអាចធ្វើវិសោធនកម្មច្បាប់ជាតិរបស់ខ្លួនបានឡើយ លើកលែងតែវិសោធនកម្មនោះធ្វើឡើងដើម្បីឱ្យស្របតាមសេចក្តីព្រាងនៃកិច្ចព្រមព្រៀង។ អាស្រ័យហេតុនេះ សេចក្តីព្រាងនៃកិច្ចព្រមព្រៀងនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់កិច្ចធានារ៉ាប់រងកាតព្វកិច្ចក្នុងការអនុវត្តតាមច្បាប់អន្តរជាតិ ដែលអង្គជំនុំជំរះវិសាមញ្ញនឹងត្រូវរៀបចំជារចនាសម្ព័ន្ធ និងចាត់តាំងឱ្យស្របតាមបទបញ្ញត្តិដែលបានចែង ហើយត្រូវដំណើរការការងារ និងអនុវត្តសិទ្ធិអំណាចរបស់ខ្លួនស្របតាមនីតិវិធីដែលបានកំណត់។

២៦. ទីពីរ រចនាសម្ព័ន្ធតុលាការមានបីថ្នាក់ដែលមានលក្ខណៈទទើសទទែង ដែលគ្រោងរៀបចំសំរាប់អង្គជំនុំជំរះវិសាមញ្ញ ក្នុងអំឡុងពេលចរចាពីលើកមុន ត្រូវបានកែប្រែកាន់តែសាមញ្ញជាងមុនរួចហើយ គឺរចនាសម្ព័ន្ធតុលាការមួយដែលមានតែពីរថ្នាក់វិញ។

២៧. ទីបី នៅក្នុងសេចក្តីព្រាងនៃកិច្ចព្រមព្រៀងមានបញ្ញត្តិមួយចំនួន ចែងអំពីនីតិវិធីដែលអង្គជំនុំជំរះវិសាមញ្ញត្រូវអនុវត្តតាមនឹងអំពីវិធីដែលអង្គនេះមានកាតព្វកិច្ចក្នុងការអនុវត្តសិទ្ធិអំណាចរបស់ខ្លួន ហើយជាងនេះទៅទៀតចែងរហូតដល់ការធានាអនុវត្តឱ្យបានស្របតាមបទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌ ភាពត្រឹមត្រូវ និងនីតិវិធីត្រឹមត្រូវតាមច្បាប់ ដែលនៅក្នុងបញ្ញត្តិនៃកិច្ចព្រមព្រៀងដែលបានធ្វើការពិភាក្សានៅក្នុងអំឡុងពេលចចារលើកមុនពុំមានចែងទេ។ សេចក្តីយោងទាក់ទងអំពីបញ្ហានេះ មានចែងនៅក្នុងផ្នែកទី IV, ឃ និង ង នៃរបាយការណ៍នេះ។

២៨. អ្វីដែលបាននិយាយរួចហើយ ខ្ញុំមិនអាចនិយាយទៀតទេ តែគ្រាន់តែរំលឹកឡើងវិញនូវរបាយការណ៍នៃតំណាងពិសេសរបស់ខ្ញុំទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជាដែលបានពិនិត្យឃើញស្របគ្នាថា តុលាការកម្ពុជាបានគោរពតិចតួចណាស់ចំពោះគោលការណ៍បឋមបំផុតនៃសិទ្ធិក្នុងការត្រូវតែបានទទួលការជំនុំជំរះក្តីប្រកបដោយយុត្តិធម៌។ អាស្រ័យហេតុនេះ ខ្ញុំនៅតែមានការព្រួយបារម្ភខ្លាចក្រែងអង្គជំនុំជំរះវិសាមញ្ញមិនគោរពពេញលេញតាមបញ្ញត្តិសំខាន់ៗនៃសេចក្តីព្រាងកិច្ចព្រមព្រៀង ហើយដូចនេះ បទដ្ឋានអន្តរជាតិដែលបានបង្កើតឡើងស្តីពីយុត្តិធម៌ ភាពត្រឹមត្រូវ និងនីតិវិធីត្រឹមត្រូវតាមច្បាប់នោះ ក៏មិនអាចធានាថាត្រូវបានគោរពដែរ។

២៩. ជាងនេះទៅទៀត ផ្អែកតាមការរកឃើញយ៉ាងច្បាស់លាស់របស់មហាសន្និបាតអង្គការសហប្រជាជាតិដូចក្នុងសេចក្តីសំរេចចិត្តរបស់ខ្លួនលេខ 57/225 ដែលចែងថាបញ្ហានៅតែមានជាបន្តទាក់ទិននឹងនីតិរដ្ឋ និងការប្រព្រឹត្តទៅនៃតុលាការកម្ពុជាដែលបណ្តាលមកពីការជ្រៀតជ្រែកពីអង្គនីតិប្រតិបត្តិទៅក្នុងឯករាជ្យភាពរបស់តុលាការនោះ។ ខ្ញុំមានបំណងយ៉ាងខ្លាំងចង់ឱ្យចែងនៅក្នុងសេចក្តីព្រាងនៃកិច្ចព្រមព្រៀងចែងថា សមាសភាពភាគច្រើនជាចៅក្រមបរទេសនៅក្នុងអង្គជំនុំជំរះវិសាមញ្ញទាំងពីរថ្នាក់វិញ។ ខ្ញុំបានយល់ឃើញ ហើយនៅតែបន្តយល់ឃើញថា ចៅក្រមបរទេសដែលមិនត្រូវពឹងផ្អែកលើអំណាចនីតិប្រតិបត្តិកម្ពុជាតាមបែបណាមួយ នោះមិនគួរទទួលឥទ្ធិពលសូម្បីតែតិចតួច ឬក៏បណ្តោយខ្លួនឱ្យមានការជ្រៀតពីមជ្ឈដ្ឋាននោះទេ។ លើសពីនេះទៅទៀត រូបមន្តស្តីពី “សំលេងភាគច្រើនលើសលុប” ដែលត្រូវបានលើយកមកចរចាដោយរដ្ឋនានាជាសមាជិក ហើយមិនដោយគណៈប្រតិភូអង្គការសហប្រជាជាតិនោះ មិនគួរចាំបាច់ត្រូវយកមកប្រើទេ។ ទន្ទឹមនឹងនេះ អង្គជំនុំជំរះវិសាមញ្ញដែលមានសារជាតិសំខាន់ជាតុលាការជាតិរបស់កម្ពុជានោះ គួររក្សាឱ្យនៅដដែលមិនត្រូវប៉ះពាល់។ មានឧទាហរណ៍ជាច្រើនអំពីតុលាការជាតិ ដែលទោះបីជាសមាសភាពចៅក្រមបរទេសមានចំនួនច្រើនលើសលុប ឬមានសុទ្ធតែចៅក្រមបរទេសទាំងអស់ក្តីក៏តុលាការទាំងនោះ នៅតែជាតុលាការជាតិរបស់រដ្ឋសាម៉ីជាដរាប។

៣០. ហេតុដូច្នេះ នៅតែមានការស្រពិចស្រពិលនៅឡើយថា តើបញ្ញត្តិនៃសេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពីរចនាសម្ព័ន្ធ និង ការចាត់តាំងនៃអង្គជំនុំជំរះវិសាមញ្ញនឹងអាចធានាឱ្យមានការជឿងទុកចិត្តបានយ៉ាងពេញលេញដែរឬទេ ដោយយោលទៅលើភាពមិនឯករាជ្យនៃតុលាការកម្ពុជា។ ទោះជាយ៉ាងណាក្តី ខ្ញុំមានសេចក្តីសង្ឃឹមថាកិច្ចព្រមព្រៀងដែលនឹងសម្រេចរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាផ្អែកលើមូលដ្ឋាននៃសេចក្តីព្រាងនេះ រដ្ឋាភិបាលកម្ពុជាមុខជានឹងអនុវត្តយ៉ាងពេញលេញ នូវកាតព្វកិច្ចដែលខ្លួនត្រូវទទួលខុសត្រូវ។ គួរគត់សំគាល់ដែរថា តាមលក្ខខ័ណ្ឌដែលបានចែងនៅក្នុងសេចក្តីព្រាងនៃកិច្ចព្រមព្រៀងនេះ បើសិនជារដ្ឋាភិបាលគេចវេះមិនអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនទេនោះ មុខជានឹងនាំឱ្យអង្គការសហប្រជាជាតិដកកិច្ចសហប្រតិបត្តិការ និងជំនួយពីកិច្ចដំណើរការនេះ។ សេចក្តីយោងទាក់ទងនឹងបញ្ហានេះ មានចែងនៅក្នុងផ្នែកទី IV, ច ខាងក្រោមនេះ។

## IV. សេចក្តីព្រាងកិច្ចព្រមព្រៀង

### ក. សារជាតិនៃអង្គជំនុំជំរះវិសាមញ្ញ

៣១. អង្គជំនុំជំរះវិសាមញ្ញមានសារជាតិតាមផ្លូវច្បាប់ជានីតិបុគ្គលដូចនីតិបុគ្គលដ៏ទៃទៀតដែរ ដែលត្រូវបានកំណត់ដោយលិខិតុបករណ៍ដែលបានបង្កើតអង្គជំនុំជំរះនេះឡើង។ អនុលោមតាមសេចក្តីព្រាងនៃកិច្ចព្រមព្រៀងនេះ អង្គជំនុំជំរះវិសាមញ្ញនឹងត្រូវបង្កើតឡើងដោយច្បាប់ជាតិរបស់កម្ពុជា។ ហេតុដូច្នេះ អង្គជំនុំជំរះវិសាមញ្ញគឺជាតុលាការជាតិរបស់កម្ពុជាដែលបានបង្កើតឡើងក្នុងរចនាសម្ព័ន្ធតុលាការនៃប្រទេសនោះ។

## ក. រចនាសម្ព័ន្ធ និងការចាត់តាំងនៃអង្គជំនុំជំរះវិសាមញ្ញ

៣២. សេចក្តីព្រាងនៃកិច្ចព្រមព្រៀងគ្រោងបង្កើតឱ្យមានស្ថាប័នសរុបចំនួនប្រាំ។ ស្ថាប័នទីមួយគឺអង្គជំនុំជំរះវិសាមញ្ញខ្លួនឯងផ្ទាល់។

## អង្គជំនុំជំរះវិសាមញ្ញសាលាដំបូង និងអង្គជំនុំជំរះវិសាមញ្ញតុលាការកំពូល

៣៣. អង្គជំនុំជំរះវិសាមញ្ញរួមមានអង្គជំនុំជំរះវិសាមញ្ញសាលាដំបូង និងអង្គជំនុំជំរះវិសាមញ្ញតុលាការកំពូល។ សាលាដំបូងជាអង្គជំនុំជំរះវិសាមញ្ញដែលមានសមាសភាពចៅក្រមខ្មែរបីរូប និងចៅក្រមបរទេសពីររូប។ តុលាការកំពូលជាអង្គជំនុំជំរះវិសាមញ្ញ ដែលមានសមាសភាពចៅក្រមខ្មែរបួនរូប និងចៅក្រមបរទេសបីរូប។ ចៅក្រមបរទេសទាំងប្រាំរូបនេះនឹងត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា ពីក្នុងបញ្ជីដែលមានបេក្ខជនមិនឱ្យតិចជាងប្រាំពីររូបដែលបញ្ជូនមក ដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ។

៣៤. ការសំរេចសេចក្តីនៅក្នុងអង្គជំនុំជំរះវិសាមញ្ញទីមួយៗ តម្រូវឱ្យមានការបោះឆ្នោតគាំទ្រពីចៅក្រមភាគច្រើន បូកមួយ នៃអង្គជំនុំជំរះវិសាមញ្ញនោះ ដែលហៅថា “ សំលេងភាគច្រើនលើសលុប ”។ ដូច្នេះ ការសំរេចសេចក្តីណាមួយមិនអាចធ្វើឡើងដោយគ្មានសំលេងគាំទ្រពីចៅក្រមបរទេសចំនួនមួយរូបយ៉ាងតិចបានឡើយ។

៣៥. អង្គជំនុំជំរះវិសាមញ្ញតុលាការកំពូលនឹងដើរតួនាទីពីរ ជាអង្គជំនុំជំរះវិសាមញ្ញសាលាឧទ្ធរណ៍ផង និងជាអង្គជំនុំជំរះចុងក្រោយផង។ ចៅក្រមនៃអង្គជំនុំជំរះវិសាមញ្ញនោះ នឹងបើកអង្គសវនាការតែនៅពេលណាដែលបានទទួលបណ្តឹងឧទ្ធរណ៍លើបញ្ហាជាពិសេសណាមួយតែប៉ុណ្ណោះ។

## សហព្រះរាជអាជ្ញា

៣៦. ត្រូវមានសហព្រះរាជអាជ្ញាចំនួនពីររូបៈ គឺព្រះរាជអាជ្ញាខ្មែរមួយរូប និងព្រះរាជអាជ្ញាបរទេសមួយរូប។ សហព្រះរាជអាជ្ញាបរទេសមួយរូប នឹងត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជាពីក្នុងបញ្ជីដែលមានឈ្មោះបេក្ខជនចំនួនពីររូប ដែលបញ្ជូនមកដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ។ បេក្ខជនមួយរូបទៀត ត្រូវបានតែងតាំងជាសហព្រះរាជអាជ្ញាបរទេសបំរុង។

៣៧. សហព្រះរាជអាជ្ញាទាំងពីររូបត្រូវផ្តួចផ្តើមរៀបចំការស៊ើបអង្កេត ធ្វើបទចោទប្រកាន់ ជំរុញបើកការសាកសួរតាមផ្លូវតុលាការ ហើយប្រសិនបើការសាកសួរទាំងនោះឈានទៅរកការនាំខ្លួនជនជាប់ចោទឡើងសវនាការនៅចំពោះមុខអង្គជំនុំជំរះវិសាមញ្ញ ត្រូវធ្វើបទចោទប្រកាន់ និងប្តឹងឧទ្ធរណ៍តាមក្រោយ។

## សហចៅក្រមស៊ើបអង្កេត

៣៨. ត្រូវមានសហចៅក្រមស៊ើបអង្កេតចំនួនពីររូប: គឺចៅក្រមស៊ើបអង្កេតខ្មែរមួយរូប និងចៅក្រមស៊ើបអង្កេតបរទេសមួយរូប។ សហចៅក្រមស៊ើបអង្កេតបរទេសមួយរូបនឹងត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជាពីក្នុងបញ្ជីដែលមានឈ្មោះបេក្ខជនពីររូប ដែលបញ្ជូនមកដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ។ បេក្ខជនមួយរូបទៀត ត្រូវតែងតាំងជាសហចៅក្រមស៊ើបអង្កេតបរទេសបំរុង។

៣៩. សហចៅក្រមស៊ើបអង្កេតទាំងពីររូបត្រូវដឹកនាំការស៊ើបអង្កេតតាមដីកាចោទប្រកាន់បឋម ដែលបានដាក់ជូនដោយសហព្រះរាជអាជ្ញា។ បើសិនជាការស៊ើបអង្កេតនោះ ប្រមូលភស្តុតាងគ្រប់គ្រាន់ហើយ ត្រូវបញ្ជូនជនជាប់ចោទនោះឡើងសវនាការនៅចំពោះមុខអង្គជំនុំជំរះវិសាមញ្ញ។

## អង្គបុរេជំនុំជំរះ

៤០. សហព្រះរាជាអាជ្ញាទាំងពីររូប ត្រូវសហការគ្នាដើម្បីឈានដល់ការឯកភាពគ្នាអំពីវិធីរួម ដើម្បីធ្វើការចោទប្រកាន់ជនល្មើស។ ក្នុងករណីដែលមានការខ្វែងគំនិតគ្នា អំពីថាតើត្រូវបន្ត ឬមិនបន្តធ្វើការចោទប្រកាន់ ការចោទប្រកាន់នឹងត្រូវធ្វើជាបន្ត បើសិនសហព្រះរាជអាជ្ញាមួយរូបមិនបានរិះរកយន្តការសំរាប់ដោះស្រាយការខ្វែងគំនិតគ្នា រវាងសហព្រះរាជអាជ្ញាទាំងពីររូបទេនោះ។ យន្តការនោះអាចជាអង្គបុរេជំនុំជំរះ។

៤១. អង្គបុរេជំនុំជំរះនឹងមានសមាសភាពចៅក្រមបីរូបដែលតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា និងចៅក្រមពីររូបទៀតតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រោយពីបញ្ជូនឈ្មោះមក ដោយលោកអគ្គលេខា-ធិការអង្គការសហប្រជាជាតិ។

៤២. សេចក្តីព្រាងនៃកិច្ចព្រមព្រៀង មានបញ្ញត្តិស្រដៀងគ្នាស្តីពីការដោះស្រាយការខ្វែងគំនិតគ្នារវាងសហចៅក្រមស៊ើបអង្កេតទាំងពីររូប ទាក់ទិននឹងការដឹកនាំស៊ើបអង្កេតតាមផ្លូវតុលាការ។

៤៣. អង្គបុរេជំនុំជំរះនឹងត្រូវកោះប្រជុំចៅក្រមរបស់ខ្លួន ដើម្បីបើកសវនាការតែនៅក្នុងករណីចាំបាច់ ឬតាមការចាំបាច់តែប៉ុណ្ណោះ។

## ការិយាល័យរដ្ឋបាល

៤៤. អង្គជំនុំជំរះវិសាមញ្ញ អង្គបុរេជំនុំជំរះ ការិយាល័យព្រះរាជាអាជ្ញា នឹងសហចៅក្រមស៊ើបអង្កេតនឹងត្រូវគ្រប់គ្រងដោយការិយាល័យរដ្ឋបាលមួយ។ ការិយាល័យនេះមានប្រធានខ្មែរមួយរូប និងអនុប្រធានបរទេសមួយរូប។ អនុប្រធានត្រូវតែងតាំងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ។ អនុប្រធាន ត្រូវទទួលខុសត្រូវលើការគ្រប់គ្រងបុគ្គលិកបរទេសនៃអង្គជំនុំជំរះវិសាមញ្ញ អង្គបុរេជំនុំជំរះ សហចៅក្រមស៊ើបអង្កេត និងការិយាល័យ ព្រះរាជាអាជ្ញា។

អនុប្រធាន ត្រូវទទួលខុសត្រូវផងដែរចំពោះការជ្រើសរើសបុគ្គលិកបរទេសទាំងអស់ដែលបំរើការជាមួយស្ថាប័នទាំងនោះ ឬក្នុងការិយាល័យរដ្ឋបាល។ រីឯប្រធានខ្មែរ មានភារកិច្ចគ្រប់គ្រងទូទៅលើការងាររបស់ការិយាល័យរដ្ឋបាល។ សមត្ថកិច្ចរបស់ប្រធាននឹងមិនមានវិសាលភាពចំពោះបញ្ហាទាំងឡាយ ដែលឋិតនៅក្រោមវិធាន និងនីតិវិធីរបស់អង្គការសហប្រជាជាតិទេ។ ប្រធាន និងអនុប្រធាន ត្រូវសហការគ្នាដើម្បីឱ្យការិយាល័យរដ្ឋបាលដំណើការការងារប្រកបដោយប្រសិទ្ធិភាព។

## គ- យុត្តាធិការនៃអង្គជំនុំជំរះវិសាមញ្ញ

### យុត្តាធិការផ្នែកតាមកម្មវត្ថុនៃករណីរឿង

៤៥. អង្គជំនុំជំរះវិសាមញ្ញមានយុត្តាធិការលើឧក្រិដ្ឋកម្មទាំងអស់ដែលមានចែងនៅក្នុងជំពូកទី II នៃច្បាប់ជាតិរបស់កម្ពុជា ចុះថ្ងៃទី ១០ សីហា ២០០១។ ឧក្រិដ្ឋកម្មទាំងនោះ រួមមានឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិដូចជា : ឧក្រិដ្ឋកម្មប្រល័យពូជ សាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩។ ឧក្រិដ្ឋកម្មក្រោមច្បាប់កម្ពុជា ត្រូវបានរួមបញ្ចូលផងដែរៈ មនុស្សឃាត ទារុណកម្ម ការវាយប្រហារលើសាសនា។ ក្រៅពីនេះមាន រួមបញ្ចូលនូវការរំលោភលើអនុសញ្ញាអន្តរជាតិដែលកម្ពុជាបានទទួលស្គាល់ៈ ការបំផ្លាញទ្រព្យសម្បត្តិវប្បធម៌ ក្នុងពេលមានជំលោះប្រដាប់អាវុធ នៅក្នុងកាលៈទេសៈដែលបានហាមឃាត់ដោយអនុសញ្ញាទីក្រុងឡាអេឆ្នាំ ១៩៥៤ ស្តីពីការការពារសម្បត្តិវប្បធម៌នៅក្នុងកាលៈទេសៈនៃជំលោះប្រដាប់អាវុធ និងឧក្រិដ្ឋកម្មប្រឆាំងជនដែលទទួលបានកិច្ច ការពារជាអន្តរជាតិក្នុងកាលៈទេសៈដែលហាមឃាត់ដោយអនុសញ្ញាទីក្រុងវីយ៉ែនឆ្នាំ ១៩៦១ ស្តីពីទំទាក់ទំនងការទូត។

### យុត្តាធិការបណ្តោះអាសន្ន

៤៦. យុត្តាធិការនៃអង្គជំនុំជំរះវិសាមញ្ញត្រូវបានកំរិតកំណត់តែចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី ១៧ មេសា ១៩៧៥ ដល់ថ្ងៃទី ៦ មករា ១៩៧៩ តែប៉ុណ្ណោះ។

### យុត្តាធិការជាបុគ្គល

៤៧. យុត្តាធិការនៃអង្គជំនុំជំរះវិសាមញ្ញត្រូវបានកំរិតកំណត់ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលឋិតនៅក្រោមយុត្តាធិ-ការផ្នែកតាមកម្មវត្ថុនៃករណីរឿង និងយុត្តាធិការបណ្តោះអាសន្ននៃអង្គជំនុំជំរះវិសាមញ្ញតែប៉ុណ្ណោះ។

### ច្បាប់នីតិវិធី

៤៨. សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជំរះវិសាមញ្ញ ត្រូវអនុវត្តតាមនីតិវិធីធម្មតាដែលមានចែងដោយច្បាប់កម្ពុជា។ ក៏ប៉ុន្តែ បើសិនជាច្បាប់កម្ពុជាមិនបានចែងអំពីបញ្ហាជាក់លាក់ណាមួយ ឬបើសិនជាមានភាពមិន

ច្បាស់លាស់ទាក់ទិននឹងការបកស្រាយ ឬការអនុវត្តវិធានពាក់ព័ន្ធណាមួយនៃច្បាប់កម្ពុជា ឬបើសិនជាមានបញ្ហាស្តីពីភាពស្របគ្នានៃវិធាននោះជាមួយបទដ្ឋានអន្តរជាតិ អង្គជំនុំជំរះវិសាមញ្ញអាចស្វែងរកការណែនាំ នៅក្នុងវិធានស្តីពីនីតិវិធីពាក់ព័ន្ធដែលបានបង្កើតឡើងក្នុងកំរិតអន្តរជាតិ ។

### ង- បទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌ ភាពត្រឹមត្រូវ និងនីតិវិធីត្រឹមត្រូវតាមច្បាប់

៤៩. សេចក្តីព្រាងនៃកិច្ចព្រមព្រៀងចែងថា អង្គជំនុំជំរះវិសាមញ្ញនឹងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនស្របតាមបទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌ ភាពត្រឹមត្រូវ និងនីតិវិធីត្រឹមត្រូវតាមច្បាប់ ដូចមានចែងក្នុងមាត្រា ១៤ និងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។ សេចក្តីព្រាងនៃកិច្ចព្រមព្រៀងបានចែងទៀតថា សិទ្ធិរបស់ជនជាប់ចោទដែលមានចែងក្នុងមាត្រាទាំងនោះនៃកតិកាសញ្ញានេះ ត្រូវតែបានគោរពតាមនៅគ្រប់ដំណាក់កាលនៃចំណាត់ការរឿងក្តីព្រហ្មទណ្ឌ ។ សេចក្តីបរិយាយជាក់លាក់ ទាក់ទងនឹងសិទ្ធិជនជាប់ចោទដែលត្រូវមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ត្រូវបានចែងធានាដោយមាត្រា ១៤ កថាខណ្ឌទី ៣ (ឃ) នៃកតិកាសញ្ញានេះ ។ កតិកាសញ្ញាបានចែងផងដែរថា ជនជាប់ចោទអាចរក ឬអាចមានមេធាវីចាត់តាំងដែលមិនមែនជាជនជាតិខ្មែរ ។ មេធាវីបរទេស ក៏ដូចជាមេធាវីសមាគមកម្ពុជាដែរ ក្នុងការការពារកូនក្តីរបស់ខ្លួន ត្រូវមានឥរិយាបទឱ្យបានស្របទៅនឹងលក្ខខណ្ឌនៃសេចក្តីព្រាងនៃកិច្ចព្រមព្រៀងច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃកម្ពុជា និងបទដ្ឋាន និងក្រមសីលធម៌វិជ្ជាជីវច្បាប់ដែលបានទទួលស្គាល់ ។

៥០. សេចក្តីព្រាងនៃកិច្ចព្រមព្រៀងក៏បានចែងជាពិសេសផងដែរអំពីសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបាននូវសវនាការជាសាធារណៈ និងប្រកបដោយភាពត្រឹមត្រូវយុត្តិធម៌ ដូចបានចែងធានាដោយមាត្រា ១៤ កថាខណ្ឌទី ១ នៃកតិកាសញ្ញា ។ ដើម្បីជាប្រយោជន៍ដល់ការធានាឱ្យមានសវនាការជាសាធារណៈ និងប្រកបដោយភាពត្រឹមត្រូវយុត្តិធម៌ និងដើម្បីធានាបានការជឿទុកចិត្តនៅក្នុងកិច្ចដំណើរការក្តីនេះ គួរតែអនុញ្ញាតឱ្យតំណាងរដ្ឋជាសមាជិក លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ និងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិព្រមទាំងប្រព័ន្ធផ្សព្វផ្សាយពត៌មានអាចមានសិទ្ធិចូលស្តាប់ និងសង្កេតការណ៍នៃកិច្ចដំណើរការជំនុំជំរះក្តីនៅចំពោះមុខអង្គជំនុំជំរះវិសាមញ្ញបានគ្រប់ពេលវេលា ។ ការអនុញ្ញាតនេះ គួរត្រូវបានបដិសេធតែនៅក្នុងករណីណាដែលចាំបាច់បំផុត តាមមតិរបស់តុលាការ និងនៅពេលដែលសវនាការជាសាធារណៈនោះអាច នឹងនាំឱ្យខូចប្រយោជន៍ក្នុងការស្វែងរកយុត្តិធម៌តែប៉ុណ្ណោះ ។

### ច- កាតព្វកិច្ចរបស់អង្គការសហប្រជាជាតិក្នុងការជួយឧបត្ថម្ភ

៥១. គោលបំណងនៃកិច្ចព្រមព្រៀងណាមួយរវាងអង្គការសហប្រជាជាតិ និងកម្ពុជាគឺដើម្បីកំណត់ពីកាតព្វកិច្ចរបស់អង្គការសហប្រជាជាតិក្នុងការជួយឧបត្ថម្ភដល់កម្ពុជាក្នុងការបង្កើតអង្គជំនុំជំរះវិសាមញ្ញ និងជួយគាំទ្រដល់កិច្ចដំណើរការរបស់អង្គជំនុំជំរះឱ្យបានប្រកបដោយនីរន្តរភាព ហើយក៏ជាគោលដៅដ៏សំខាន់ជាមូលដ្ឋាននៃកិច្ចព្រមព្រៀងណាមួយបែបនេះ ដើម្បីបញ្ជាក់ឱ្យបានច្បាស់ពីទម្រង់បែបផែននៃការជួយឧបត្ថម្ភដែលអង្គការសហប្រជាជាតិត្រូវផ្តល់ដើម្បីសំរេចតាម

គោលដៅនោះ។ បើសិនជាអង្គការសហប្រជាជាតិ ត្រូវតែយល់ព្រមក្នុងការផ្តល់ជំនួយជួយឧបត្ថម្ភបែបនេះ គេគ្រាន់តែចង់ឱ្យលិខិតុបករណ៍ដែលចែងកំណត់អំពីកាតព្វកិច្ចនោះ កំណត់ឱ្យបានច្បាស់លាស់អំពីប្រភេទនៃស្ថាប័នដែលត្រូវទទួលភារកិច្ចក្នុងការជួយរៀបចំបង្កើត និងដំណើរការអង្គជំនុំជំរះវិសាមញ្ញនេះ។ សេចក្តីព្រាងនៃកិច្ចព្រមព្រៀងចែងតើអង្គជំនុំជំរះវិសាមញ្ញត្រូវរៀបចំជារចនាសម្ព័ន្ធ និងការចាត់តាំងយ៉ាងដូចម្តេច? ហើយតើអង្គជំនុំជំរះនេះត្រូវដំណើរការការងាររបៀបណា? ដើម្បីទទួលការជួយឧបត្ថម្ភពីអង្គការសហប្រជាជាតិ។ តាមលក្ខណៈតក្កវិជ្ជា នៅពេលក្រោយបើសិនជារដ្ឋាភិបាលធ្វើការកែប្រែរចនាសម្ព័ន្ធ និងការចាត់តាំងនៃអង្គជំនុំជំរះវិសាមញ្ញ ដែលនាំឱ្យខុសពីកិច្ចព្រមព្រៀងនេះ ជាលទ្ធផលគឺ កាតព្វកិច្ចរបស់អង្គការសហប្រជាជាតិដែលត្រូវផ្តល់ជំនួយក្រោមកិច្ចព្រមព្រៀងនេះនិងត្រូវបញ្ឈប់លែងអនុវត្ត។ លទ្ធផលដូចគ្នានេះអាចនឹងកើតមានដែរ បើសិនជារដ្ឋាភិបាលធ្វើឱ្យអង្គជំនុំជំរះវិសាមញ្ញដំណើរការខុសពីកិច្ចព្រមព្រៀង។ នៅក្នុងសេចក្តីព្រាងនៃកិច្ចព្រមព្រៀងបានចែងរក្សាសិទ្ធជូនអង្គការសហប្រជាជាតិក្នុងការបញ្ឈប់ការផ្តល់ជំនួយជាយកថាហេតុ ក្នុងករណីខាងលើនេះ។

## V. ដំណាក់កាលបន្ទាប់

៩២. ស្ថានភាពបច្ចុប្បន្ននៃសេចក្តីព្រាងកិច្ចព្រមព្រៀងមានដូចតទៅនេះ៖ លោកទីប្រឹក្សាច្បាប់អ.ស.ប ជាតំណាងរបស់ខ្ញុំ និងលោក ទេសរដ្ឋមន្ត្រី សុខ អាន ជាតំណាងរបស់រដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាសង្ខេបលើសេចក្តីព្រាងនៃកិច្ចព្រមព្រៀង។ គួរបញ្ជាក់ដែរថាភាគីទាំងពីរមិនទាន់បានចុះហត្ថលេខាលើសេចក្តីព្រាងនៃកិច្ចព្រមព្រៀងនៅឡើយទេ គឺគ្រាន់តែចុះហត្ថលេខាសង្ខេបតែប៉ុណ្ណោះ។ ពួកគេបានបញ្ជាក់ថា ការដែលគ្រាន់តែចុះហត្ថលេខាសង្ខេបដូចនេះ ព្រោះនេះគឺជាអត្ថបទដែលពួកគេបានរៀបចំឡើង ដើម្បីផ្ញើមួយ ឬច្រើនច្បាប់ ជូនអាជ្ញាធរពាក់ព័ន្ធរបស់ខ្លួនធ្វើការពិនិត្យពិចារណា ។ ម្យ៉ាងឥឡូវនេះគឺជាពេលដែលម្ខាងគឺមហាសន្និបាតអ.ស.ប និងម្ខាង ទៀតគឺអាជ្ញាធរធម្មនុញ្ញពាក់ព័ន្ធនៃកម្ពុជា ដើម្បីសំរេចថាតើត្រូវចុះ ឬមិនចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ហើយបើសិនជាត្រូវចុះហត្ថលេខានោះ តើត្រូវចុះនៅលើអត្ថបទដែលបានចុះហត្ថលេខាសង្ខេបរួច ឬក៏ត្រូវធ្វើការកែសម្រួលលើអត្ថបទនោះរួចសិន សឹមចុះហត្ថលេខា។ ការចុះហត្ថលេខាសង្ខេបលើអត្ថបទនៃកិច្ចព្រមព្រៀងនោះ មិនបានហាមឃាត់មិនឱ្យគូភាគីអាចសំរេចបន្តការចរចាតាមត្រូវការលើបញ្ហាមួយចំនួនមុនពេលសំរេចចុះកិច្ចព្រមព្រៀងជាចុងក្រោយនោះទេ។

៩៣. មាត្រា ៣០ នៃសេចក្តីព្រាងកិច្ចព្រមព្រៀងចែងថា ដើម្បីបង្ខំឱ្យគូភាគីត្រូវតែអនុវត្តតាម កិច្ចព្រមព្រៀងត្រូវតែអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ហើយត្រូវផ្តល់សច្ចានុមតិដោយអាជ្ញាធរធម្មនុញ្ញពាក់ព័ន្ធនៃកម្ពុជា។ បើសិនជាមហាសន្និបាតយល់ឃើញថា ខ្លួនមានបំណងចង់ឱ្យមានការសំរេចចុះហត្ថលេខាជាចុងក្រោយលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាផ្អែកលើសេចក្តីព្រាងដែលមានភ្ជាប់ជាឧបសម្ព័ន្ធនៃរបាយការណ៍នេះ គឺអង្គការសហប្រជាជាតិចាំបាច់ត្រូវអនុម័ត លើសេចក្តីសំរេចមួយដើម្បីយល់ព្រមលើសេចក្តីព្រាងដែលមានភ្ជាប់ជាឧប-

សម្ព័ន្ធនេះ។ ក្នុងករណីមហាសន្និបាតអ.ស.ប អនុម័តយល់ព្រមលើសេចក្តីព្រាងនោះ បន្ទាប់ពីនេះខ្ញុំនឹងបន្តចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះជូនអង្គការសហប្រជាជាតិ។

៥៤. មាត្រា ៣៤ នៃសេចក្តីព្រាងកិច្ចព្រមព្រៀងចែងថា បន្ទាប់ពីបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ និងបានផ្តល់សច្ចានុមតិដោយអាជ្ញាធរចម្មនុញ្ញពាក់ព័ន្ធនៃកម្ពុជារួចហើយ សេចក្តីព្រាងនៃកិច្ចព្រមព្រៀងនឹងចូលជាធរមាននៅពេលដែលភាគីទាំងពីរបានជូនដំណឹងគ្នាទៅវិញទៅមកជាលាយលក្ខអក្សរថា សេចក្តីតម្រូវតាមផ្លូវច្បាប់ដើម្បីចូលជាធរមានត្រូវបានអនុវត្តតាមរួចហើយ។ សំនួរថាតើពេលណាទើបខ្ញុំនឹងផ្តល់ការជូនដំណឹងនេះ គឺវាអាស្រ័យលើសេចក្តីសំរេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលើយន្តការហិរញ្ញវត្ថុ ដែលអ.ស.ប នឹងប្រើប្រាស់សំរាប់ផ្តល់ជំនួយអន្តរជាតិក្រោមសេចក្តីព្រាងនៃកិច្ចព្រមព្រៀងនេះ។ បញ្ហានេះ ត្រូវបានលើកឡើងនៅក្នុងផ្នែកទី VI, ខ , ខាងក្រោមនេះ :

**VI. ការអនុវត្តជាក់ស្តែង**

៥៥. កាលបើត្រូវបានសេចក្តីព្រាងនៃកិច្ចព្រមព្រៀងនេះ អនុម័តយល់ព្រមហើយនោះ មុខជាធ្វើឱ្យមានកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមករវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងការតែងតាំងចៅក្រមនៃអង្គជំនុំជំរះវិសាមញ្ញ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ចៅក្រមនៃអង្គបុរេជំនុំជំរះ និងប្រធាន អនុប្រធាន និងបុគ្គលិកការិយាល័យរដ្ឋបាល។ សេចក្តីព្រាងនៃកិច្ចព្រមព្រៀងនេះ ក៏មានចែងផងដែរ នៅក្នុងមាត្រា ១៤, ១៥, ១៦ និងមាត្រា ១៧ អំពីកាតព្វកិច្ចរបស់គូភាគីទាក់ទងនឹងការផ្តល់ទីតាំង ការចេញចំណាយលើប្រាក់បៀវត្ស និងបរិលាភនៃមន្ត្រី និងបុគ្គលិក និងការចេញចំណាយលើសោហ៊ុយសំរាប់កិច្ចដំណើរការការងារនៃអង្គជំនុំជំរះវិសាមញ្ញ និងស្ថាប័នពាក់ព័ន្ធនៃអង្គជំនុំជំរះនេះ។

**ក. តម្រូវការដែលបានប៉ាន់ប្រមាណ**

៥៦. ថ្វីបើបច្ចុប្បន្នមិនទាន់មានកត្តាសំរាប់គិតគូសព្វគ្រប់ក៏ដោយ ក៏តាមការប៉ាន់ស្មានគឺត្រូវការថវិកាដែលមានទឹកប្រាក់ជាង 19 លានដុល្លារសហរដ្ឋអាមេរិកសំរាប់ការបង្កើត និងសំរាប់កិច្ចប្រតិបត្តិការការងារនៃអង្គជំនុំជំរះវិសាមញ្ញ ការិយាល័យព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជំរះ និងការិយាល័យរដ្ឋបាលបាន សំរាប់រយៈពេលជាងបីឆ្នាំ - បីឆ្នាំនេះគឺជារយៈពេលមួយ ដែលគេសន្មត់ថារាល់ការជំនុំជំរះ និងការប្តឹងឧទ្ធរណ៍នឹងត្រូវបានធ្វើចប់សព្វគ្រប់គិតចាប់ពីពេលដែលការិយាល័យព្រះរាជអាជ្ញាបានចាប់ផ្តើមដំណើរការការងារ។

បុគ្គលិក

៥៧. ក្រោមសេចក្តីព្រាងនៃកិច្ចព្រមព្រៀងនេះ អង្គការសហប្រជាជាតិនឹងទទួលខុសត្រូវចំពោះប្រាក់បៀវត្ស និងបរិលាភ នៃចៅក្រមបរទេស ដោយរួមទាំងសហចៅក្រមស៊ើបអង្កេតបរទេស សហព្រះរាជាអាជ្ញាបរទេស អនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិកបរទេសដែលតម្រូវដោយអង្គជំនុំជំរះវិសាមញ្ញ សហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជាអាជ្ញា និងការិយាល័យរដ្ឋបាល ។

៥៨. លោកអគ្គលេខាធិការនឹងមិនធ្វើការតែងតាំងចៅក្រមបរទេស សហព្រះរាជាអាជ្ញាបរទេស សហចៅក្រមស៊ើបអង្កេតបរទេសទេ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា នឹងធ្វើការតែងតាំងជនទាំងនោះ ពីក្នុងបញ្ជីឈ្មោះដែល និងដាក់ស្នើដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ។ ការអនុវត្តបែបដូចនេះ នៅក្នុងកាលៈទេសៈធម្មតាគឺធ្វើឱ្យមានការលំបាក និងចាត់ទុកមន្ត្រីទាំងនោះថាជាមន្ត្រីរបស់អង្គការសហប្រជាជាតិណាស់។ ក៏ប៉ុន្តែ យោលដោយអង្គការសហប្រជាជាតិជាអ្នកទទួលបន្ទុកក្នុងការចេញចំណាយលើប្រាក់បៀវត្ស និងបរិលាភដល់មន្ត្រីទាំងនោះផងនោះ អ.ស.ប ក៏មានបំណងខ្លាំងក្លាចង់ឱ្យមន្ត្រីទាំងនោះទទួលបានឋានៈជាមន្ត្រីរបស់អង្គការសហប្រជាតិផ្អែកទៅតាមគោលបំណងនៃលក្ខខណ្ឌបំរើការងារ។

៥៩. ហេតុដូចនេះ បើសិនជាមហាសន្និបាតអ.ស.ប សំរេចអនុម័តសេចក្តីព្រាងនៃកិច្ចព្រមព្រៀងនេះ សូមស្នើជាអនុសាសន៍ថា គួរតែធ្វើជាសេចក្តីសំរេចជាក់លាក់មួយ ដើម្បីនឹងទទួលស្គាល់មន្ត្រីទាំងនោះថាជាមន្ត្រីរបស់អង្គការសហប្រជាជាតិផ្អែកទៅតាមគោលបំណងនៃលក្ខខណ្ឌបំរើការងារ។

៦០. ការរៀបចំបង្កើត និងកិច្ចប្រតិបត្តិការនៃអង្គជំនុំជំរះវិសាមញ្ញត្រូវរួមបញ្ចូលនូវដំណាក់ការចាប់ផ្តើមការងារដែលផ្អែកទៅតាមជំហានរីកចំរើន នៃចំណាត់ការតាមផ្លូវច្បាប់ - មានន័យថាទទួលឥទ្ធិពលពីសន្ទុះជឿនលឿនទៅតាមដំណាក់កាលនៃការស៊ើបអង្កេត ការជំនុំជំរះ និងការប្តឹងឧទ្ធរណ៍។ តាមគោលបំណងនៃកិច្ចព្រមព្រៀងនេះ គេសន្មត់ថារាល់ការជំនុំជំរះ និងការប្តឹងឧទ្ធរណ៍ទាំងអស់នឹងត្រូវចប់សព្វគ្រប់ក្នុងរយៈពេលបីឆ្នាំបន្ទាប់ពីសហព្រះរាជអាជ្ញាបានចាប់ផ្តើមដំណើរការការងាររបស់ខ្លួន។ ទាក់ទងនឹងបញ្ហានេះ បើសិនជាសេចក្តីព្រាងនៃកិច្ចព្រមព្រៀងត្រូវបានអនុម័ត ការខិតខំប្រឹងប្រែងត្រូវតែបានធ្វើឡើងដើម្បីជំរុញបង្កើតការិយាល័យព្រះរាជអាជ្ញា និងការិយាល័យរដ្ឋបាលឱ្យបានឆាប់រហ័ស។ តាមការប៉ានប្រមាណជាហ៊ានដំបូងបង្ហាញឱ្យឃើញថា សំរាប់រយៈពេលបីឆ្នាំនេះ ចំណាយសំរាប់បុគ្គលិកគឺមានទឹកប្រាក់សរុប 18.2 លាន ដុល្លាអាមេរិក (ទឹកប្រាក់ចំណាាយដុល)។

៦១. នៅក្នុងឆ្នាំទី១ នៃកិច្ចប្រតិបត្តិការ គេបានប៉ាន់ប្រមាណថាធនធានគិតជាទឹកប្រាក់ចំនួន 4.2 លានដុល្លារអាមេរិ (ទឹកប្រាក់ដុល) និងត្រូវចំណេយទៅលើតំណែងចំនួន ៨០ កន្លែង ទាក់ទងនឹងដំណាក់កាលនៃការរៀបបង្កើតអង្គជំនុំជំរះវិសាមញ្ញ និងសហចៅក្រមស៊ើបអង្កេត និងការរៀបចំបង្កើតការិយាល័យព្រះរាជអាជ្ញា និងការិយាល័យរដ្ឋបាលទាំង

ស្រុង។ ការិយាល័យទាំងនោះ នឹងត្រូវបំពេញការងាររបស់ខ្លួនយ៉ាងពេញសមត្ថភាព នៅក្នុងរយៈពេលបីឆ្នាំពេញនៃកិច្ចប្រតិបត្តិការនេះ។

៦២. គេបានរំពឹងទុកថា តម្រូវការសំរាប់ឆ្នាំទីពីរនៃកិច្ចប្រតិបត្តិការនឹងត្រូវកើនឡើងដល់កំពូល នៅពេលដែលអង្គជំនុំជំរះវិសាមញ្ញ និងសហចៅក្រមស៊ើបអង្កេតប្រតិបត្តិការការងារពេញទំហឹង។ ក៏ប៉ុន្តែ អង្គជំនុំជំរះវិសាមញ្ញសាលាឧទ្ធរណ៍នឹងដំណើរការការងាររបស់ខ្លួនតែក្នុងរយៈពេលតិចជាងមួយឆ្នាំពេញប៉ុណ្ណោះ។ ទាក់ទងរឿងនេះ ធនធានដែលបានប៉ាន់ប្រមាណមានទឹកប្រាក់ 7.8 លានដុល្លារអាមេរិក (ទឹកប្រាក់ដុល) សំរាប់ចំណាយលើតំណែងបំពេញបន្ថែមចំនួន ៩១ កន្លែងទៀត។

៦៣. នៅឆ្នាំទីបី គេរំពឹងថាអង្គជំនុំជំរះវិសាមញ្ញសាលាដំបូង និងសហចៅក្រមស៊ើបអង្កេតនឹងត្រូវបិទការិយាល័យ ឬបំពេញការងាររបស់ខ្លួនឱ្យបានចប់សព្វគ្រប់។ រីឯ អង្គជំនុំជំរះវិសាមញ្ញសាលាឧទ្ធរណ៍វិញត្រូវដំណើរការងាររបស់ខ្លួនពេញមួយឆ្នាំ។ ដូចនេះ តាមការប៉ាន់ស្មានតម្រូវការធនធានសំរាប់ឆ្នាំទីបី នឹងត្រូវថយចុះមកនៅត្រឹមក៏រិតតែ 6.2 លានដុល្លារអាមេរិក (ទឹកប្រាក់ដុល) ដែលនឹងត្រូវផ្តល់សំរាប់តំណែងបំពេញបន្ថែមចំនួន ៧៤ កន្លែងទៀត។

**ទីតាំង**

៦៤. អនុលោមតាមមាត្រា ១៤ នៃសេចក្តីព្រាងកិច្ចព្រមព្រៀងនេះ រដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកក្នុងការចំណាយទៅលើទីតាំងសំរាប់ការរៀបចំបង្កើតអង្គជំនុំជំរះវិសាមញ្ញ ការិយាល័យព្រះរាជអាជ្ញា ចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជំរះ និង ការិយាល័យរដ្ឋបាល។ នៅក្នុងពេលទស្សនកិច្ចរបស់ខ្លួនទៅកាន់រាជធានីភ្នំពេញ ក្រុមអង្គការសហប្រជាជាតិបានទៅទស្សនកិច្ចទីតាំងចំនួនបីកន្លែង ដែលរដ្ឋាភិបាលបានស្នើជាយោបល់ថាជាទីតាំងដែលមានលក្ខណៈសមស្របសំរាប់គោលបំណងនេះ។ ទីតាំងនោះរួម មានសាលមហោស្រពចតុមុខ (ដែលរដ្ឋាភិបាលបានយល់ឃើញថា អាចនឹងធ្វើជាបន្ទប់សវនាការបាន) អាគារសាលាក្រុង និងអាគារក្រសួងយុត្តិធម៌។ ទីតាំងទាំងពីរក្រោយនេះ ត្រូវទាមទារឱ្យមានវិធានការការជួសជុលកែលំអរឡើងវិញ ដើម្បីបំពេញតាមតម្រូវការ។ តាមមាត្រា ១៧ (ច) នៃសេចក្តីព្រាងកិច្ចព្រមព្រៀង ការទទួលខុសត្រូវ និងការចំណាយសំរាប់រៀបចំជញ្ជាំងខ័ណ្ឌផ្នែកខាងក្នុង និងការកែលំអរតិចតួចបន្ថែមសំរាប់គោលបំណងធ្វើជាបន្ទប់ការិយាល័យពាក់ព័ន្ធនានា គឺជាបន្ទុករបស់អង្គការសហប្រជាជាតិ។

៦៥. នៅចុងបញ្ចប់នៃដំណើរទស្សនកិច្ចទៅកាន់រាជធានីភ្នំពេញ ក្រុមអង្គការសហប្រជាជាតិមិនទាន់មានជំហ៊រច្បាស់លាស់ចំពោះទីតាំងណាមួយដែលរដ្ឋាភិបាលកម្ពុជាបានស្នើឡើងនោះទេ ហើយរដ្ឋាភិបាលកម្ពុជានៅកំពុងបន្តថ្លឹងថ្លែងអំពីជំរើសផ្សេងៗ ដោយរួមទាំងលទ្ធភាពក្នុងការសាងសង់ទីតាំងថ្មីទៀតផង។ ផ្អែកតាមនេះ មិនទាន់មានបញ្ញត្តិណាចែងបញ្ចូលក្នុងថវិកាប៉ាន់ស្មានអំពីចំណាយដែលអង្គការសហប្រជាជាតិត្រូវទទួលបន្ទុកទាក់ទងនឹងការរៀបចំជញ្ជាំងខ័ណ្ឌផ្នែកខាងក្នុង និងការកែលំអរតិចតួចនៃទីតាំងដែលអាចនឹងកើតមានជាយថាហេតុ។

**គ្រឿងសង្ហារឹម និងគ្រឿងបរិក្ខារ**

៦៦- ដូចគ្នានឹងករណីនៃដំណាក់កាលដាក់ពង្រាយបុគ្គលិកដែរ ការបំពាក់គ្រឿងសង្ហារឹម និងគ្រឿងបរិក្ខារសំរាប់បង្កើតអង្គជំនុំជំនុំជំរះវិសាមញ្ញ និងស្ថាប័នពាក់ព័ន្ធនៃអង្គជំនុំជំរះនេះ ត្រូវអនុវត្តតាមគំរូដូចគ្នា។ ធនធានដែលតម្រូវសំរាប់រយៈពេលជាង ៣ ឆ្នាំ តាមការប៉ាន់ស្មាន មានទឹកប្រាក់ 372.300 ដុល្លារអាមេរិក។ ទឹកប្រាក់នេះ នឹងត្រូវផ្តល់សំរាប់បំពាក់នូវៈ គ្រឿងសង្ហារឹមសំរាប់ការិយាល័យ និងផាសុបករណ៍សំរាប់ស្តុកទុក គ្រឿងស្វ័យប្រវត្តិសំរាប់ការិយាល័យ និងគ្រឿងឧបករណ៍សំរាប់រក្សាទិន្នន័យ ដូចជា LAN Servers, កុំព្យូទ័រប្រភេទដាក់លើតុ ម៉ាស៊ីនថតចម្លង ម៉ាស៊ីនស្កែន និងម៉ាស៊ីនហ្វាក្ស គ្រឿងទូរគមនាគមន៍ (ទូរស័ព្ទដៃ និងទូរស័ព្ទខ្សែ ) និងរថយន្ត។ គេសង្ឃឹមថាគ្រឿងសង្ហារឹម និងគ្រឿងបរិក្ខារទាំងមូល១ និងត្រូវគេយកមកបំពាក់នៅក្នុងអំឡុងឆ្នាំទី១ នៃកិច្ចប្រតិបត្តិការ (ក្នុងទឹកប្រាក់ 350.000 ដុល្លារអាមេរិក)។ គេរំពឹងទុកថា នៅក្នុងឆ្នាំទី ៣ នៃកិច្ចប្រតិបត្តិការ មិនចាំបាច់ត្រូវការបំពាក់គ្រឿងបរិក្ខារបន្ថែមទៀតទេ។

**ការធ្វើដំណើរ**

៦៧. ការគ្រោងទុកត្រូវបានធ្វើឡើងនៅក្នុងការប៉ាន់ស្មានក្នុងជំហ៊ានដំបូងសំរាប់ការធ្វើដំណើររវាងទីក្រុងញូវយ៉ក និងរាជធានីភ្នំពេញយ៉ាងហោចណាស់ក៏ម្តងដែរក្នុងមួយឆ្នាំ សំរាប់ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជំរះ (ដែលតាមការរំពឹងគ្រោងទុកនោះគឺត្រូវការរយៈពេល ១០ ថ្ងៃសំរាប់ចៅក្រមម្នាក់១ ក្នុងមួយឆ្នាំ) និងសំរាប់អនុប្រធានរដ្ឋបាល (ដើម្បីទៅពិគ្រោះពិភាក្សាយោបល់នៅឯទីបញ្ជាការអ.ស.ប និងចូលបង្ហាញខ្លួននៅចំពោះមុខអង្គនីតិបញ្ញត្តិ)។ ថវិកានេះនឹងមានទឹកប្រាក់ប្រមាណជា 31.500 ដុល្លារក្នុងមួយឆ្នាំ ឬទឹកប្រាក់សរុប 94.500 ដុល្លារសំរាប់រយៈពេលបីឆ្នាំ។

៦៨. នៅពេលនេះ មិនទាន់មានការគ្រោងទុកនៅឡើយទេសំរាប់ការធ្វើដំណើរក្នុងស្រុក ឬការធ្វើដំណើររបស់សាក្សីពីក្នុង និងក្រៅប្រទេសកម្ពុជា ដូចបានបញ្ជាក់ក្នុងមាត្រា ១៧ (ឃ) នៃសេចក្តីព្រាងកិច្ចនៃព្រមព្រៀង។

**ការចំណាយទូសំរាប់កិច្ចប្រតិបត្តិការទូទៅ**

៦៩. ការគ្រោងទុកជំហ៊ានដំបូងសំរាប់រយៈពេលបីឆ្នាំនៃកិច្ចប្រតិបត្តិការរបស់អង្គជំនុំជំរះវិសាមញ្ញ និងស្ថាប័នពាក់ព័ន្ធរបស់អង្គជំនុំជំរះនេះ មានទឹកប្រាក់ប្រមាណជា 324.900 ដុល្លារត្រូវបានគិតបញ្ចូលក្នុងការប៉ាន់ស្មានជំហ៊ានដំបូងទាំងនេះសំរាប់បំរើឱ្យសេចក្តីត្រូវការផ្សេង១ សំរាប់កិច្ចប្រតិបត្តិការការងារ ដោយរាប់បញ្ចូលទាំងការចំណាយសំរាប់ទិញធានារ៉ាប់រង ប្រេងឥន្ធនៈ និងការថែទាំរថយន្តជាដើម ។ល។

៧០. ក៏ប៉ុន្តែចំណាយសំរាប់គ្រឿងផាសុបករណ៍ និងសេវាចាំបាច់ផ្សេង១ សំរាប់កិច្ចប្រតិបត្តិការការងារនៃអង្គជំនុំជំរះវិសាមញ្ញ និងស្ថាប័នពាក់ព័ន្ធនៃអង្គជំនុំជំរះដែលនឹងត្រូវចែងក្នុងកិច្ចព្រមព្រៀងដាច់ដោយឡែកមួយទៀតរវាងអង្គការសហប្រជាជាតិ និងកម្ពុជា មិនទាន់បានរាប់បញ្ចូលក្នុងការប៉ាន់ស្មាននេះនៅឡើយទេ។

៧១. ការគ្រោងទុកនូវប្រាក់បំណាច់សំរាប់មេធាវីដែលអាចនឹងត្រូវបានចាត់តាំងដើម្បីការពារជនជាប់ចោទដែលក្រីក្រ និងសំរាប់ចំណាយទៅលើសកម្មភាពការងារចោទប្រកាន់ និងស៊ើបអង្កេត ការផ្គត់ផ្គង់ និងសំភារៈ ការបោះពុម្ព ការចុះកិច្ចសន្យាបំរើការងារផ្សេងៗ និងជំនួយឧបត្ថម្ភទូទៅជាបណ្តោះអាសន្នក៏មិនទាន់បានរាប់បញ្ចូលនៅឡើយដែរ ។

## ខ. យន្តការហិរញ្ញវត្ថុ

៧២. ក្នុងកថាខណ្ឌទី ៩ នៃសេចក្តីសំរេចចិត្តលេខ 57/228 នៃមហាសន្និបាតអង្គការសហប្រជាជាតិបានស្នើសុំឱ្យខ្ញុំដាក់បញ្ចូលក្នុងរបាយការណ៍នេះ នូវអនុសាសន៍ស្តីពី " ទឹកប្រាក់វិភាគទានស្ម័គ្រចិត្ត គ្រឿងបរិក្ខារ និងសេវាផ្សេងៗដល់អង្គជំនុំជំរះវិសាមញ្ញ ក្នុងចំណោមថវិកាផ្សេងទៀត " តាមរយៈការផ្តល់បុគ្គលិកជំនាញដែលចាំបាច់ពីរដ្ឋជាសមាជិក និងពីបណ្តាអង្គការអន្តររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល" ។

៧៣. កាលពីថ្ងៃទី ២២ វិច្ឆិកា ២០០២ ក្នុងខណៈដែលមហាសន្និបាតអង្គការសហប្រជាជាតិកំពុងពិចារណាលើសេចក្តីព្រាងនៃសេចក្តីសំរេចចិត្តរបស់ខ្លួនលេខ 57/228 ខ្ញុំបានផ្ញើលិខិតមួយច្បាប់លេខ (A/57/626) ជូនប្រធានមហាសន្និបាត និងបានបញ្ជាក់ថាខ្ញុំមានបំណងដាក់បញ្ចូលនូវពត៌មានស្តីពីសេចក្តីត្រូវការផ្នែកហិរញ្ញវត្ថុនៃអង្គជំនុំជំរះវិសាមញ្ញ នៅក្នុងរបាយការណ៍ដែលខ្ញុំនឹងដាក់ជូនមហាសន្និបាតអ.ស.ប ស្របតាមកថាខណ្ឌប្រតិបត្តិទី ៧ នៃសេចក្តីព្រាងសេចក្តីសំរេចចិត្ត។ ខ្ញុំបានបញ្ជាក់ថែមទៀតថារបាយការណ៍ក៏ត្រូវដាក់បញ្ចូលផងដែរនូវសំណើស្តីពីវិធីក្នុងការផ្តល់មូលនីធិដោយរួមទាំងការផ្តល់មូលនីធិតាមរយៈវិភាគទានដែលបានសំរេចកំណត់រួចហើយ ។

៧៤. ខ្ញុំយល់ឃើញថាកិច្ចប្រតិបត្តិការប្រភេទនេះ ត្រូវបានកំណត់តួនាទីភារកិច្ចដោយរដ្ឋជាសមាជិក នឹងបង្កើតបានជាការចំណាយមួយរបស់អង្គការ អនុលោមតាមមាត្រា ១៧ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ និងគួរត្រូវបានផ្តល់តាមរយៈវិភាគទានដែលបានសំរេចកំណត់រួចហើយ ។ យន្តការហិរញ្ញវត្ថុដែលផ្អែកលើវិភាគទានស្ម័គ្រចិត្តនឹងមិនផ្តល់ប្រភពថវិកាគ្រប់គ្រាន់ និងជាប់លាប់តាមសេចក្តីត្រូវការចាំបាច់ដើម្បីអាចលទ្ធភាពតែងតាំងចៅក្រម សហព្រះរាជអាជ្ញាបរទេស សហចៅក្រមស៊ើបអង្កេតបរទេស និងអនុប្រធានការិយាល័យរដ្ឋបាល ដើម្បីចុះកិច្ចសន្យាជួលបុគ្គលិករដ្ឋបាល និងបុគ្គលិកជំនួយការដើម្បីបំរើការងារ និងដើម្បីទិញគ្រឿងបរិក្ខារដែលចាំបាច់។ ហើយវាក៏មិនអាចផ្តល់មូលដ្ឋានគត់មត់សំរាប់ដឹកនាំការងារស៊ើបអង្កេត ការចោទប្រកាន់ និងការជំនុំជំរះបានដែរ ។

៧៥. កិច្ចប្រតិបត្តិការរបស់តុលាការមិនត្រូវទុកឱ្យគាំងដំណើរដោយសាតែការប្រែប្រួលមិនធម្មតានៃវិភាគទានស្ម័គ្រចិត្តនោះទេ។ គេអាចនិយាយបានថា តុលាការផ្អែកតាមគោលការណ៍រដ្ឋធម្មនុញ្ញ គួរត្រូវបានផ្តល់ថវិកាតាមរយៈពន្ធដា ឬនៅកំរិតអន្តរជាតិតាមរយៈយន្តការស្រដៀងគ្នានឹងវិភាគទានដែលបានសំរេចកំណត់រួចហើយ ។

៧៦. ក្រៅពីនេះ ឆ្លងតាមបទពិសោធជាមួយតុលាការពិសេសនៅប្រទេសសេរ៉ាលេអូន បានបង្ហាញឱ្យឃើញថា បើសិនជាអង្គការសហប្រជាជាតិត្រូវផ្តល់ជំនួយ តាមរយៈវិភាគទានស្ម័គ្រចិត្ត គឺត្រូវចំណាយពេលរហូតទៅជាងមួយឆ្នាំឯណោះមុននឹងទទួលបានវិភាគទានគ្រប់គ្រាន់អាចដំណើរការការងារបាន។ ទាក់ទងបញ្ហានេះ ខ្ញុំមិនអាចធ្វើអ្វីបានក្រៅតែរំលឹកឡើងវិញថា នេះគឺជាបំណងប្រាថ្នារបស់មហាសន្និបាតអង្គការសហប្រជាជាតិ ដែលមានចែងនៅក្នុងសេចក្តីសំរេចចិត្តរបស់ខ្លួនលេខ 57/228 ដែលចង់ឱ្យបង្កើតអង្គជំនុំជំរះវិសាមញ្ញឱ្យបានយ៉ាងឆាប់តាមដែលអាចធ្វើទៅបាន ហើយចាប់ផ្តើមដំណើរការភ្លាមៗ។ បើពុំដូច្នោះទេ នឹងត្រូវបាត់បង់ឱកាសក្នុងការនាំខ្លួនជនដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដើម្បីយកមកកាត់ទោសជាក់ជាពុំខានឡើយ។ តាមទស្សនៈរបស់ខ្ញុំ មានតែវិធីមួយគត់ ដើម្បីធានាមិនឱ្យកើតមានបញ្ហាដូចនេះ គឺត្រូវផ្តល់ជំនួយតាមរយៈវិភាគទានដែលបានសំរេចកំណត់រួចហើយ។ ធ្វើដូចនេះ នឹងផ្តល់ឱ្យមានយន្តការថវិកាមួយដែលអាចដំណើរការបានងាយស្រួល និងប្រកបដោយនិរន្តរភាពធានាបាននូវការផ្តល់មូលនីធិគ្រប់គ្រាន់និងជាប់លាប់។ ហើយក៏នឹងនៅតែបើកចំហសំរាប់រដ្ឋជាសមាជិក អង្គការអន្តររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនានាក្នុងការចូលរួមវិភាគទានស្ម័គ្រចិត្តដើម្បីគោលបំណងនៃកិច្ចការពិសេសនេះ។

៧៧. បីទោះជាបំណងប្រាថ្នារបស់មហាសន្និបាតអង្គការសហប្រជាជាតិថាជំនួយដែលអង្គការសហប្រជាជាតិដែលត្រូវផ្តល់ជូនអង្គជំនុំជំរះវិសាមញ្ញក្រោមកិច្ចព្រមព្រៀងមួយជាមួយរដ្ឋាភិបាលកម្ពុជា គួរត្រូវបានផ្តល់តាមរយៈវិភាគទានស្ម័គ្រចិត្តនោះក៏ដោយក៏កិច្ចដំណើរការនៃការបង្កើតអង្គជំនុំជំរះវិសាមញ្ញ - កិច្ចដំណើរការក្នុងការជ្រើសតាំង និងជួលបុគ្គលិក ការផ្គត់ផ្គង់គ្រឿងបរិក្ខារ ។ល។ - និងអាចផ្តួចផ្តើមគំនិតធ្វើទៅបាននោះគឺលុះត្រាតែមានថវិកាគ្រប់គ្រាន់ដើម្បីចំណាយសំរាប់បុគ្គលិក និងកិច្ចប្រតិបត្តិការការងារដែលចាំបាច់នៃអង្គជំនុំជំរះវិសាមញ្ញសំរាប់រយៈពេលមួយជាប់លាប់សិន។

៧៨. ខ្ញុំដឹងថាមានរដ្ឋជាសមាជិកជាច្រើន បានធ្វើសេចក្តីថ្លែងការណ៍ក្រៅផ្លូវការដែលគួរឱ្យសង្ឃឹមទុកចិត្តថាមុខជានឹងបានទទួលនូវវិភាគទានស្ម័គ្រចិត្ត ដែលត្រូវការចាំបាច់នៅក្នុងពេលដ៏ឆាប់រហ័ស និងពេញលេញ ដើម្បីផ្តល់ជូនអង្គការសហប្រជាជាតិសំរាប់ការចំណាយលើអង្គជំនុំជំរះវិសាមញ្ញ។ ក៏ប៉ុន្តែ ខ្ញុំក៏ធ្លាប់ទទួលនូវការធានាអះអាងគាំទ្រក្រៅផ្លូវការស្រដៀងគ្នានេះដែរ កាលពីករណីនៃ តុលាការពិសេសសំរាប់ប្រទេសសេរ៉ាឡាអូន។

## VII. សេក្តីសន្នដ្ឋាន

៧៩. របាយការណ៍នេះ រៀបរាប់អំពីជំហ៊ាននៃវិធានការដែលខ្ញុំបានចាត់ដើម្បីបន្តកិច្ចចរចាជាមួយរដ្ឋាភិបាលកម្ពុជាសំរាប់កិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គជំនុំជំរៈវិសាមញ្ញក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ ដើម្បីកាត់ទោសចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ របាយការណ៍នេះក៏បានរៀបរាប់ផងដែរអំពីសេចក្តីព្រាងនៃកិច្ចព្រមព្រៀងដែលត្រូវបានសំរេចជាចុងក្រោយ ដោយសារលទ្ធផលនៃការចរចាទាំងនោះ។ ជាងនេះទៅទៀត នៅក្នុងរបាយការណ៍ អត្ថបទត្រូវបានកែលំអរយ៉ាងច្រើនលើអត្ថបទចាស់ដែលបានពិភាក្សាក្នុងពេលចរចា

កន្លងមកនេះ បានពន្យល់អំពីហេតុអ្វីបាននៅតែមានការសង្ស័យនៅឡើយចំពោះភាពមិនច្បាស់លាស់ ថាតើអាចធានាការជឿទុកចិត្តលើអង្គជំនុំជំរះវិសាមញ្ញបានឬទេ អំពីឯករាជ្យភាពនៃតុលាការកម្ពុជាយ៉ាងនេះ។

៨០. បើសិនជាមហាសន្និបាតយល់ឃើញថា អង្គការសហប្រជាជាតិគួរបន្តកិច្ចពិភាក្សាតទៅទៀតដើម្បីសំរេចចុះកិច្ចព្រមព្រៀងមួយជាមួយរដ្ឋាភិបាលកម្ពុជាដោយផ្អែកតាមសេចក្តីព្រាងនោះ របាយការណ៍នេះគោងរៀបរាប់អំពីជំហ៊ាននៃវិធានការដែលនឹងត្រូវចាត់ធ្វើដើម្បីសំរេចតាមគោលបំណងនេះ។ មិនចាំបាច់និយាយទេតឺ ខ្ញុំមុខតែត្រូវខិតខំប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីអនុវត្តកិច្ច ព្រមព្រៀងនេះហើយ។

៨១. បើសិនជាកិច្ចព្រមព្រៀងនេះចូលជាធរមាន ខ្ញុំយល់ឃើញថាសំខាន់បំផុតគឺ អង្គការសហប្រជា ជាតិត្រូវជួយធានាធ្វើយ៉ាងណាឱ្យអង្គជំនុំជំរះវិសាមញ្ញដំណើរការការងារឱ្យបានស្របតាមកិច្ចព្រមព្រៀង និងឱ្យគោរពតាមបទដ្ឋានអន្តរជាតិដែលបានរៀបរាប់ខាងលើ។ អាស្រ័យហេតុនេះ ខ្ញុំសូមស្នើឱ្យអង្គការសហប្រជា ជាតិគួរតែបន្តចូលរួមជាដដែលតទៅទៀត ក្នុងការត្រួតពិនិត្យលើការអនុវត្តសេចក្តីព្រាងនៃកិច្ចព្រមព្រៀងនេះ។

៨២. របាយការណ៍នេះបន្តរៀបរាប់ពីតម្រូវការរបស់អង្គជំនុំជំរះវិសាមញ្ញ និងស្ថាប័នពាក់ព័ន្ធនៃអង្គជំនុំជំរះនេះ ទាក់ទងនឹងបញ្ហាថវិកា បុគ្គលិក និងសេវា។ របាយការណ៍ក៏បានទាក់ទាញការយកចិត្តទុកដាក់ផងដែរ អំពីសេចក្តីត្រូវការឱ្យមានយន្តការហិរញ្ញវត្ថុមួយដែលគត់មត់ និងអាចដំណើរការបាន ដើម្បីធ្វើឱ្យជំនួយដែលត្រូវផ្តល់ដោយអង្គការសហប្រជាជាតិដល់អង្គជំនុំជំរះវិសាមញ្ញបានប្រកបដោយនិរន្តរភាព នៅក្នុងអំឡុងពេលនៃកិច្ចប្រតិបត្តិការរបស់ខ្លួន។ របាយការណ៍បានសន្និដ្ឋានថា វិភាគទានដែលបានសំរេចកំណត់រួច តំណាងឱ្យយន្តការដូចនេះតែមួយគត់ ដែលគត់មត់និងអាចដំណើរការបានប្រកបដោយនិរន្តរភាព ហើយដែលអាចធានាដល់ការបង្កើតអង្គជំនុំជំរះវិសាមញ្ញបានឆាប់ទាន់ពេលវេលា និងចាប់ផ្តើមការងាររបស់ខ្លួនយ៉ាងឆាប់រហ័សបំផុត។

**កំណត់សំគាល់**

---

[១] សេចក្តីសំរេចចិត្តលេខ 57/228 នៃមហាសន្និបាតអង្គការសហប្រជាជាតិ កថាខណ្ឌទីប្រាំពីរនៃបុព្វកថា ហើយក៏សូមអានផងដែរនូវកថាខណ្ឌទីប្រាំបីនៃបុព្វកថា។ នៅក្នុងកថាខណ្ឌក្រោយនេះ មហាសន្និបាតអង្គការសហប្រជាជាតិបានសំដែងស្វាគមន៍និយាយជាទូទៅចំពោះការប្រកាសឱ្យប្រើ កាលពីថ្ងៃទី ១០ សីហា ២០០១ នូវច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលច្បាប់នេះ បានផ្តល់នូវសំនួនសេចក្តីសំរាប់ជាគោលគំនិតនេះ។ នៅក្នុងកថាខណ្ឌដដែលនេះ មហាសន្និបាតក៏បានកត់សំគាល់យ៉ាងជាក់លាក់ដោយធ្វើការវាយតម្លៃខ្ពស់ចំពោះប្រការច្បាប់ ដែលបានចែងអំពីជំនួយអន្តរជាតិដែលនឹងបានផ្តល់តាមរយៈអង្គការសហ-ប្រជាជាតិសំរាប់ការបង្កើត និងប្រតិបត្តិការនៃអង្គជំនុំជំរះវិសាមញ្ញ។

---

[២] សូមអានកថាខណ្ឌទី ២ និងទី ៣ នៃសេចក្តីសំរេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិ។ ហើយក៏សូមអានផងដែរនូវកថាខណ្ឌទីប្រាំបីនៃបុព្វកថា ដែលក្នុងនោះ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តយល់ព្រមយ៉ាងជាក់លាក់លើជំពូកទី ១ ស្តីពី "បទប្បញ្ញត្តិទូទៅ" និងជំពូកទី ២ ស្តីពី "សមត្ថកិច្ច" នៃច្បាប់ជាតិរបស់កម្ពុជា ដែលកំណត់ពីយុត្តាធិការចំពោះបុគ្គល និងផ្អែកតាមកម្មវត្ថុនៃករណីរឿងនៃអង្គជំនុំជំរះវិសាមញ្ញ។

[៣] សូមអានកថាខណ្ឌទី ៤ (ខ) នៃសេចក្តីសំរេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិ។ ហើយក៏សូមអានផងដែរនូវកថាខណ្ឌទីដប់នៃបុព្វកថាដែលក្នុងនោះ មហាសន្និបាតអង្គការសហប្រជាជាតិបានសំដែងស្វាគមន៍ចំពោះកិច្ចពិភាក្សាដែលខ្ញុំបានធ្វើឡើងជាមួយរដ្ឋាភិបាលកម្ពុជា បន្ទាប់ពីសេចក្តីថ្លែងការណ៍របស់ខ្ញុំកាលពីថ្ងៃទី ៨ កម្ភៈ ២០០២។ នៅក្នុងអំឡុងពេលពិភាក្សានោះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានជំរាបជូនខ្ញុំតាមរយៈលិខិតមួយច្បាប់ ចុះថ្ងៃទី ២៨ មិថុនា ២០០២ ថាលោកបានត្រៀមលក្ខណៈរួចហើយក្នុងការធ្វើឱ្យមានលក្ខណៈសាមញ្ញ នូវរចនាសម្ព័ន្ធតុលាការដែលមានបីថ្នាក់ ដែលបានគ្រោងទុកសំរាប់ការបង្កើតអង្គជំនុំជំរះវិសាមញ្ញនៅក្នុងច្បាប់កម្ពុជា ដោយការបន្ថយចំនួនពីបីថ្នាក់ឱ្យមកនៅត្រឹមតែពីរថ្នាក់វិញ។

[៤] សូមអានកថាខណ្ឌទី ៤ (ក) នៃសេចក្តីសំរេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិ។ ហើយក៏សូមអានផងដែរនូវកថាខណ្ឌទី ៦។

[៥] សូមអានកថាខណ្ឌទី ៥ នៃសេចក្តីសំរេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិ។ បទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌ ភាពត្រឹមត្រូវ និងនីតិវិធីត្រឹមត្រូវតាមច្បាប់ ដូចមានចែងក្នុងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រួមមានសិទ្ធិទទួលបាននូវការជំនុំជំរះក្តីដែលប្រកបដោយយុត្តិធម៌ ដែលធ្វើឡើងដោយសាលាជំរះក្តីឯករាជ្យ និងមិនលំអៀង។ អាស្រ័យហេតុនេះ កថាខណ្ឌទី ៤ (ក) និងកថាខណ្ឌទី ៦ នៃសេចក្តីសំរេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជា-ជាតិក៏ត្រូវបានគេយល់ថាអាចយកមកធ្វើជាលក្ខខ័ណ្ឌដែលកិច្ចព្រមព្រៀងណាមួយត្រូវតែគោរពតាមដែរ។

ក្រៅពីមាត្រា ៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌ ភាពត្រឹមត្រូវ និងនីតិវិធីត្រឹមត្រូវតាមច្បាប់ ដែលបានចែងយោងនៅក្នុងកថាខណ្ឌទី៥ នៃសេចក្តីសំរេចចិត្តរបស់មហាសន្និបាតអង្គការសហ-ប្រជាជាតិក៏មានចែងផងដែរនៅក្នុងសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (មាត្រា ១០) គោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី និងគោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា គោលការណ៍ទាំងពីរនេះត្រូវបានអនុម័តដោយអង្គសមាជលើកទី ៨ របស់អង្គការសហប្រជាជាតិ ស្តីពីការទប់ស្កាត់ បទល្មើស និងប្រព្រឹត្តកម្មចំពោះជនល្មើស ដែលធ្វើឡើងនៅទីក្រុងឡាហាវ៉ាន កាលថ្ងៃទី ២៧ កញ្ញា ១៩៩០ និងគោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពនៃតុលាការ ដែលអនុម័តយល់ព្រមដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅក្នុងសេចក្តី សំរេចចិត្តរបស់ខ្លួនលេខ 40/32 ចុះថ្ងៃទី ២៩ វិច្ឆិកា ១៩៨៥ និងនៅក្នុង សេចក្តីសំរេចចិត្តលេខ 40/146 ចុះថ្ងៃទី ១៣ ធ្នូ ១៩៨៥។

[៦] សូមអានកថាខណ្ឌទី ១, ៩ និង ទី ១០ នៃសេចក្តីសំរេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិ។ ហើយក៏សូមអានផងដែរនូវកថាខណ្ឌទី ៤ នៃបុព្វកថា។

[៧] សូមអានកថាខណ្ឌទី ១ នៃសេចក្តីសំរេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិ។

[៨] សូមអានសេចក្តីសំរេចចិត្តលេខ 57/225 ផ្នែកទី II កថាខណ្ឌទី ២។

[៩] សូមអានសេចក្តីសំរេចចិត្តថ្មីៗ ចុងក្រោយបង្អស់ លេខ A/57/230 និង E/CN.4/2003/114 ។